~Reçu le 19-9-57-

INDOCHINE FRANÇAISE
RÉGIE
DÉPÔT LÉGAL

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៣ លេខ ២

octobre

ខែ តុលា ព.ស. ២៤៩៤

ឆ្នាំសិក្សា ១៩៥១ - ៥២.

BIBLIOTHEQUE
NATIONALE
DU CAMBODGE
K_2
-1952
(2)

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្តីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

| បញ្ជីរឿង | ទំព័រ |
| --- | --- |
| វិធីបង្រៀនអក្សរបែបថ្មីនៅកុមារដ្ឋាន (សេចក្ដីណែនាំ) | ៣ |
| ឧត្ដមដ្ឋាន - មជ្ឈមដ្ឋានទី ២ ភាសា | ១១ |
| មជ្ឈិមដ្ឋានទី ១ អាទិកដ្ឋាន ភាសា | ១៧ |
| កុមារដ្ឋាន - បរិវច្ឆណដ្ឋាន ភាសា | ២៥ |
| មជ្ឈិមដ្ឋានទី២ - ឧត្ដមដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ - ធរណីមាណសាស្ត្រ | ៣៨ |
| អាទិកដ្ឋាន - មជ្ឈមដ្ឋានទី ១ នព្វន្ត | ៤៣ |
| មជ្ឈិមដ្ឋានទី ១ និងអាទិកដ្ឋាន - ធរណីមាណសាស្ត្រ | ៦៤ |
| កុមារដ្ឋាន បរិវច្ឆណដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៦៦ |
| មជ្ឈិមដ្ឋានទី ២ - ឧត្ដមដ្ឋាន - វិទ្យាសាស្ត្រ - វិធីបង្ការរោគ | ៧៨ |
| អាទិកដ្ឋាន - មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. | ៨១ |
| បរិវច្ឆណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ | ៩៥ |
| លោកនិតី សំរាប់ ៤ ថ្នាក់ | ១១០ |
| មេសូត្រតមាត់ | ១០៤ |

# សេចក្ដីណែនាំ

សិស្សស្គាល់តួអក្សរ និងជើងអក្សរ អស់ហើយ ៗ ត្រូវយកតួអក្សរមួយ ផ្សំនឹងជើងអក្សរមួយ ៗ ។

ឧបមាដូចជា (ក) ដាក់ជើង (្ង) បានជា (ក្ង):

១.– ត្រូវសរសេរ (ក្ង) នៅក្ដារខៀន ហើយឲ្យសិស្សអានម្នាក់ម្ដង - មួយពួកម្ដង ៗ

២.– ឲ្យសិស្សរកពាក្យណាដែលមានសំឡេង (ក្ង)

៣.– ត្រូវសរសេរពាក្យនោះត ៗ គ្នានៅលើក្ដារខៀន

៤.– ឲ្យសិស្សអានពាក្យទាំងនោះម្នាក់ម្ដង មួយពួកម្ដង ៗ

បង្រៀន (ក្ដ) (ក្ន) ។ល។ ក៏ប្រើរបៀបដូចខាងលើនេះដែរ ។

---

## ក្ង - ក្ដ - ក្ន - ក្ប - ក្ម - ក្រ - ក្ល - ក្ស - ក្អ

ក្ងោះ ក្ងួ(រ) ក្ដា(រ) ក្ដៅ ក្បួ(រ) ក្បោះ ក្រគ(រ)

ក្រញាំ ក្រទីក្រទា ក្របៅ ក្រពះ ក្រមុំ ក្រយៅ ក្រមួ ក្រមៀ

ក្រៃ ក្រៅ ក្លា ក្លុំ ក្អី ក្អែ

បៅក្រំដន្ទុំដំរះគ្គី ។ ក្របីឈ (រ) ក្បែ (រ) គោ ។ បៃពៅ ក្រញីហាំបី ។ ចីកុំដិះនាក់ទៅក្របេះ ។ ក្មេីហាំគៅពីសាតែក្រយាក្តៅ ។ តារសៅកេះក្រម (រ) ដំណៅ ។ ពូឈុំដើ (រ) ក្រទីក្រតា ។

---

## ខ្ច - ខ្ជ - ខ្ញ - ខ្ន - ខ្ណ - ខ្ត - ខ្ម - ខ្យ - ខ្វ - ខ្ល - ខ្ស

ខ្ចី ខ្ចៅ ខ្ជី ខ្ជា ខ្ញី ខ្ញុំ ខ្ញាំ ខ្នុះ ខ្នះ ខ្ណា(រ) ខ្តុ(រ) ខ្មោះ ខ្មី ខ្មេះ
ខ្មែ(រ) ខ្មៅ ខ្មោះ ខ្វា ខ្វី ខ្វៅ ខ្វះ ខ្លា(រ) ខ្លែះ ខ្លះ ខ្សែ ខ្សោះ

តាមៅខ្ចីខ្មៅដៃតាសៅ ។ ខ្មែ(រ)បេះដាំខ្ញី ។ គេខ្លា(រ)ក្រពើ ។ ខ្វាខ្វះគោ ។ គាពៅលីខ្នោះ ។ អាឆាំស៊ីខ្ចៅ ។ ដំបៅគាកែហ្វូ(រ)ខ្នុះ ។ កុំស(រ)សេ(រ)ខ្ជីខ្ជា ។ ខ្ញុំលោះខ្សែដៃពីគេ ។

---

## គ្ន គ្ម គ្រ ឃ្ន ឃ្ម ឃ្វ ឃ្ល

គ្នីគ្នា គ្នេ(រ) គ្រី គ្រហូ គ្រហើ គ្រាទេះ គ្រាប្រ គ្រិហា គ្រិះ គ្រុះ
គ្រូ គ្រែ គ្រោះ គ្រុំ គ្រាំ គ្រា
ឃ្មោះ ឃ្មុំ ឃ្វា ឃ្វេ ឃ្វៃ ឃ្វុំសេះ ឃ្វាំបោ(រ)

អាម៉ៅកាចាំគ្នីគ្នាត់ ៗ ចៅធំសំពះលោកគ្រូ ៗ ខ្ញុំចុះពីលើគ្រែ ៗ តាសំខ្ចីឈ្មោះចៃផៃ ៗ យាយ្ញ៉ិទំនៅក្បែរ(រ)ប៉ាឆា ៗ ពូឈុំបេះឃ្មុំសេះ ៗ គ្រានេះ គ្រូខ្ញុំស(រ)សេ(រ)តែបឃ្យា ៗ

---

## ច្ប - ច្រ - ឆ្ក - ឆ្គ - ឆ្ង - ឆ្ដ - ឆ្ន - ឆ្ព - ឆ្ម - ឆ្ល ឆ្អ

ច្បា(រ) ចោះ ច្បោះ ច្រមុះ ច្រាក់ ច្រឡា ច្រឡោះ ចោះច្រឡំ ច្រុះ ច្រែះ ច្រោះ ឆ្កា ឆ្កើះ ឆ្កែ ឆ្គាំ ឆ្ដោ ឆ្នៃ ឆ្នាំ ឆ្ពោះ ឆ្មា ឆ្នាំ ឆ្លេឆ្លា ឆ្លុះ ឆ្លោ ឆ្អើ(រ) ឆ្អេះ ឆ្អៅ ៗ

តាកែ ថៃ ច្បា(រ)ដំណាំ ៗ អាម៉ៅកាឆ្កើះ ខ្ចៅនាឡិកា ៗ ខ្ញុំចាំឆ្នាំ គីឆ្នាំថោះ ៗ គេដើ(រ)ឆ្ពោះទៅបំ កា(រ) ៗ ឆ្កែតាប៊ូខាំឆ្មាចៃសៅ ៗ ឆ្នាំក់ដើ(រ) ឆ្លេឆ្លា ៗ នៅទីនេះឆ្អេះអី ? កុំច្រឡំគំន(រ) ៗ

---

## ជ្រ - ជ្វ - ឈ្ង - ឈ្ន - ឈ្ម - ឈ្ល - ឈ្វ

ជ្រអោ ជ្រនំ ជ្រលិះ ជ្រិះ ជ្រុះ ជ្រេ ជ្រែ ជ្រៃ ជ្រោះ ជ្រៅ ជ្រំ ជ្រាំ ជ្រះ ជ្វា - ជ្វាលា ៗ ឈ្នះ ឈ្នៃ ឈ្មោះ ឈ្លី ឈ្លោះ ៗ

ខ្លាឃ្មុំនោះឈ(រ)ជ្រដើរ ។ នាឡិកាខ្ញុំជ្រុះខ្លៅ ។ កុំនៅក្បែរជ្រាំ នេះ ។ ជ្រោះនោះជ្រៅ ។ ខ្មែ(រ)ខ្ទះបេះកាសាផ្កាជ្រៅជ្រះ ។ សេះខ្ញុំខ្មៅ ឈ្មោះសេះចៅកែបឺ ។ ជីតាអាម៉ៅឈ្មោះអី? ។ កុំឈ្លោះគ្នានៅវេលា គ្រាក្រ ។

---

## ត្ង ត្ន ត្ប ត្ម ត្រ ត្ល ត្វ ត្អ

ត្បា(រ) ត្នះ ត្របះ ត្រដំ ត្រឈៃ ត្រដ(រ) ត្រសុំ ត្រសេះ ត្រខ្ញុំ ត្រា ត្រាដូ ត្រ ត្រេះត្រុះ ត្រែ ត្រេះ ត្រុំ ត្រាំ សាត្រា ត្ងៃ ត្ងុំ ត្ងា ត្អួ ។

អាខ្មៅ ត្បា(រ) ប្រមុះ ។ តាសៅទៅធ្នុះត្រីឆ្អា ។ អាខាំត្រដ(រ) ដើ(រ)ទៅណា? ។ អាម៉ៅយួ(រ)ត្រីឆ្អើ(រ) ។ គេបោះត្រាលើ ឃ្នោះ ។ ចៅឈុំទៅខ្ចីសាត្រាគេបីខ្សែ ។ គ្រូកុំទៅត្រាំខ្នា(រ)

---

## ថ្ក ថ្ង ថ្ន ថ្ត ថ្ម ថ្ល ថ្វ

ថ្ក(រ) ថ្ងូ(រ) ថ្ងៃ ថ្នូ(រ)ថ្នេ(រ) ថ្នំ ថ្មី ថ្មើ(រ) ថ្មៃ ថ្លា ថ្លៃ ថ្លៃថ្នូ(រ) ថ្វីដៃ ថ្វៃ ។

តាម៉ៅថ្ប(រ) ថាក់ឈើប្រមុះ ។ ថ្ងៃសៅ(រ) ខ្ញុំទៅត្រាំខ្ព(រ) ថ្នាំ-
គ្រូសៅតូកែ ។ តាពៅលើថ្នូទៅណា? ។
តារីទាផាសំឡៃថ្ងៃថ្ព(រ) ។ រទេះជីណៃនៅថ្នី ។ តា(រ)នេះផាចូដែគ្រូ
ខ្ញុំ ។ ថ្ងៃនោះបុះពីក្រាបេះ ។

---

## ទ្រ ទ្វ ធ្ន ធ្ម ធ្យ ធ្ល ធ្វ

ទ្រគោះ ទ្រនំ ទ្រហោ ទ្រូ ត្រាំទ្រ ទ្វា(រ)
ធ្មី ធ្នៃ ធ្វា ធ្នុះ ធ្មូ ធ្លោ ធ្វះ ធ្វើ
តាផៅទំលើទ្រនំ ។ ចៅកែទ្រហោយំ ។ តាពៅលើទ្រូទៅណា? គេខ្ញុំ
ត្រាំទ្រធំជីផាយូ(រ)ថ្ងៃ ។ ទ្វា(រ)នេះធំ ។ តាម៉ៅខ្ញុំធ្មុតាឡូ ។ ចៃសៅ
រំដៅឡធ្នៃ ។ គេដើ(រ)ក្រៅធ្វា ។ មេឃុំទៅធ្វើកា(រ) ។

---

## ប្ដ ប្រ ប្ល

ប្ដី ប្ដូ(រ) ប្រកា(រ) ប្រខាំ ប្រគំ ប្រចី ប្រដេះ ប្រជុំ ប្រឈ្លោះ
ប្រដេប្រដៅ ប្រណី ប្រទះ ប្របេះ ប្រផេះ ប្រពៃ តាប្រមា ប្រលេះ
ប្រវា ប្រឡៅក្ដែ ប្រសើ(រ) ប្រហើ(រ) ប្លែ ត្រាំបី ប្លាជួ ចៃតាំ ៣

ហៅឆ្ដី ៗ តាមៅប្ដូ(រ)ខ្សែនាឡិកា ៗ ឆ្កែចីឃុំប្រខាំគ្នា ៗ តាកែដើ(រ) ទៅប្រទះខ្លាឃ្មុំ ៗ សេះប្រផេះឈ្មោះសេះខ្មៅ ៗ ពូឈុំធ្វើប្រឡៅឆ្កែ ៗ នៅទីនោះគេប្រជុំគ្នាធ្វើអី ៗ សំឡនេះជុំប្រហើ(រ) ៗ ម៉ែខ្ញុំពីសាត្រី ផ្លាធ្ម ៗ

---

ផ្ក ផ្គ ផ្ជ ផ្ឈ ផ្ដ ផ្ត ផ្ទ ផ្ន ផ្ល ផ្យ ផ្អ

ផ្កា ផ្គ(រ) ផ្ដួ ផ្គុំ ផ្ជុំ ផ្ញើ ផ្ដាសា ផ្ដែផ្ដាំ ផ្ដៅ ផ្ដុំ ផ្ទី ផ្ទើ(រ) ផ្ទែ ផ្ទះ ផ្ល(រ) ផ្លែ ផ្ជុំ ផ្សា(រ) ផ្សំផ្គុំ ផ្សែផ្សំ ផ្សាំ ផ្សះ ផ្សះផ្សា ផ្អ(រ) ផ្អេះ ៗ

អាតាំបេះផ្កាចំប៉ាប្រាំ ៗ ស្ទូ(រ)ផ្គ(រ)នេះខ្ទួខ្ទារ ៗ ពូសៅផ្ញើត្រី ផ្ដោទៅចិផា ៗ តាកែទៅបេះផ្លែផ្ដៅ ៗ ទៅក្រំផ្សះផ្សាគ្គី ៗ ចែសំពីសា សំឡប្រហើរផ្ទី ៗ ចិកុំឈឺពោះផ្អេះ ៗ ៗ គេផ្សំថ្នាំផ្សះដំបៅ ៗ

---

ព្ន ព្យ ព្រ ព្ល ព្អ ភ្ជ ភ្ញ ភ្ដ ភ្ន ភ្ល

ព្នែ ព្នៅ ព្យាធី ព្យុះ ព្យួ(រ) កំព្រា ព្រឺ ព្រែ ព្រែ ព្រែទគ(រ) ព្រោះ ព្រៅ ព្រំ ព្រាំ ព្រះ ព្លីកា(រ) ព្អិះ ភ្ជា(រ) ភ្ញួ(រ) ភ្ញាំ ភ្ដី

ភ្នំ ភ្លា ភ្លី ភ្លើ ភ្លឺ ភ្លោះ ភ្លៅ អាម៉ៅស៊ីផ្លែពោធិ ៗ បែពោធិ៍ញ(រ)
ត្រីឆ្អើរក្បែ(រ)ឆ្នើរ ៗ ចៅកំព្រានេះថ្លូ(រ) ថាក្រ ៗ ចៅកែបង្នាំព្រឹត
ព្រៃខគ(រ) ៗគាកែក្ជួ(រ) បំកា(រ)ៗ គេបុះពីភ្នំក្រពើ ៗ ចែកុំពីសាភ្លាត្រី
ត្លា ៗ គេចុះបំភ្លីព្រៃ . ៗ

---

ម្ក ម្ខ ម្ទ ម្ជ ម្ឈ ម្ង ម្ល ម្ស ម្ន ម្យ ម្រ ម្ត ម្ហ ម្អ

ម្ជូ(រ) ម៉្ងែម្ងំ ម្នី ម្នា ម្នោ ម្នះ ម្រំ ម្រះព្រៅ ម្ទិះ ម្ជូព្រៃ
យូ(រ) ម្ទេះ ម្ទោះ ៗ ម្យា ផ្សុំ ម្ហេះ ៗ ៗ

ចែជាតីសាសំឡម្ជូ(រ)ព្រីព្រា ៗ តាកែម្នីម្នានៅផ្ទះ ៗ ពូឈុំដាំផ្កាម្ទិះ ៗ
បែពៅឈើអីយូ(រ) ម្ទះ ៗ ហ៊ានៅឈូម្យាឡើងមេឿ ៗ នៅទីនេះជុំអ្វីម្ហេះៗ
អាឆាំទៅបេះម្រះព្រៅ ៗ

---

ល្ក ល្ខ ល្គ ល្ង ល្ប ល្ព ល្ម ល្យ ល្វ ល្ហ ល្អ

ល្ងីល្ងើ (ល្ងោះ) ល្បី ល្បះ ល្ពៅ ល្មី ល្មើ ល្មែ ល្មា ល្វៃ ល្ហែ ល្អី ល្អះ ៗ
អាសៅឈើទៅជាល្ងីល្ងើ ៗ បែខាំធ្មេល្ពៅទៅដីតា ៗ ត្រីប្រាស៊ីផ្លែល្ហុ ៗ
ចីៗល្ហែតែថ្ងៃសៅ(រ) ៗ គាកែបេះផ្លើល្អីល្អ ៗ ៗ ថ្នាំគ្រួសល្បីជាយូ(រ)
ឆ្នាំ ៗ គេដាំល្ងនៅក្បែ(រ)ភ្នំ ៗ

# ស្ត ស្គ ស្ង ស្ញ ស្ដ ស្ណ ស្ន ស្យ ស្ព ស្ម ស្រ ស្ល ស្វ ស្អ

ស្កា(រ) ស្កាំ ស្គ(រ) ស្ងោ(រ) ស្ញែ ស្ដី ស្ដៅ ស្ណុះ ស្ណោះ ស្នា ស្នោ ស្បៃ ស្ពឺ ស្ពែ ស្មា ស្មោ ស្រកក ស្រគំ ស្រង៉ែ ស្រណោះ ស្រទំ ស្រឡៅ ស្រី ស្រែ ស្វា ស្វែ ស្វា ស្អុះ ស្អំ ។

អាម្ចិះស្ងោ(រ)ស្នោ ៗ ចៅកំព្រានេះដំបុ៉ីស្ញែ ៗ គេបេះផ្លែស្ដៅ ៗ ចែខាំស្ណែល្ង ៗ ស្រីក្រមុំនោះធ្វើនំផ្កាស្នោ ៗ ហ៊ើកៅពីសាស្ពែធាងក្របីស៊ីស្មៅខ្ចី ៗ ថ្ម នេះដុះស្លែ ៗ ស្វាបេះផ្លែល្វា ៗ តាកែស្អំដៃស្ដាំ ៗ

# ឧត្តមដ្ឋាន

## សោមនស្ស

អ្នកមានប្រាថ្នានឹងឲ្យបានជាមនុស្សល្អ ជាមនុស្សស្គាល់ផ្លូវសុចរិត នឹងការប្រព្រឹត្តល្អដល់គ្នានឹងគ្នាឬទេ? ចូរកុំទុកច្បាប់ធម៌ជាអំពើទម្ងន់បន្ទុំឲ្យប្រតិបត្តិតាមឡើយ ចូរអ្នកត្រងត្រាប់ដោយរីករាយដោយសោមនស្ស ។ បើគ្មានសោមនស្សហើយ អំពើមានប្រយោជន៍ចិត្តជាកុសលនឹងសេចក្ដីចំរើននៃចិត្តនឹងតាំងនៅពុំបានឡើយ ។

លុះដល់ទៅមុខ អ្នកនឹងចូលទៅក្នុងអាជីវប្បវត្តិ អ្នកនឹងប្រទះនឹងមនុស្សពាលដែលនិយាយដល់អ្នកថា “ធម្មក្រិត្យសេចក្ដីត្រឹមត្រូវ សេចក្ដីស្រឡាញ់ប្រស្រ័យមនុស្សទុកដូចជាសន្ដាន សេចក្ដីទាំងនេះជាទីប្រហ” ។ ចូរអ្នកអាសូរមនុស្សពាលទាំងនោះផង គ្នាពុំបានដឹងជាក់នូវពាក្យប្រហទេ គឺប្រហនេះឯងដែលអាចឲ្យមានជាតិខ្ពង់ខ្ពស់ហើយនឹងលំអក្នុងអាជីវប្បវត្តិ ។ អ្នកនឹងប្រទះមនុស្សវិចិកិច្ឆាដែលនឹងនិយាយដល់អ្នកថា “គឺអំពើឆ្គួតទេដែលធ្វើឲ្យមនុស្សប្រព្រឹត្តត្រឹមត្រូវ មនុស្សទាំងឡាយជាមនុស្សដូចៗគ្នា សឹងមានឫស្យាសឹងពាលដរាប” ។ ចូរអ្នកអាសូរដល់មនុស្សកំឡៅទាំងនោះផង មនុស្សទាំងនោះពុំបានដឹងថា មនុស្សជាន់

ដើមជាមនុសអសប្បុរសមួយពាន់ដង ជាមនុស្សពាលកំណាច ជាមនុស្សគាគ្រក់ជាងមនុស្សទាំងឡាយក្នុងសម័យឥឡូវទេ វាមិនដឹងឡើយថាអាជីវប្បវត្តិនៃមនុស្សបើបានស្រួលបន្តិចៗ នឹងល្អឡើងពីព្រោះមនុស្សដែលមានសេចក្ដីស្រឡាញ់នូវអំពើល្អ បានប្រព្រឹត្តល្អ បានតយុទ្ធនឹងសេចក្ដីកំឡោ ៗ គឺការប្រព្រឹត្តរបស់មនុស្សទាំងនោះ ដែលយើងគប្បីតាមហើយធ្វើឲ្យរឹតតែប្រសើរមាំមួនឡើងទៀត ៗ

កុមារទាំងឡាយ ៖ សព្វថ្ងៃនេះគឺអ្នកពល់គ្នាហើយដែលត្រូវធ្វើឲ្យបានទៅជាមនុស្សសប្បុរសប្រពៃ ហើយស្រឡាញ់អ្នកទាំងពួងដូចញាតិផៅក្នុងកាលខាងមុខ ៗ អំពើនោះជាអំពើទម្ងន់ ប៉ុន្តែដើម្បីនឹងនាំឲ្យបានសេចក្ដីល្អ ចូរអ្នកនឹកទៅអត្ថរបស់ពាក្យ ៣ ម៉ាត់គឺ ប្រាជ្ញា ចេតនានឹងសោមនស្ស ៗ

## ពន្យល់ពាក្យ

សោមនស្ស = សេចក្ដីរីករាយចិត្ត ៗ អាជីវប្បវត្តិ = ការរកស៊ីចិញ្ចឹមជីវិត ៗ ធម្មក្រិត្យ = ច្បាប់ទូន្មាន ៗ ទីប្រហា = ទីឥតគោលចារិក ៗ វិចិកិច្ឆា = គ្មានជំនឿ ជឿប្រាកដ គឺចេះតែសង្ស័យមិនដាច់ស្រេច ៗ ប្

សញ្ញា ឬ ឥស្សា = ឈ្នានីស ។ ចេតនា = ចិត្ត ។ ចិត្តជាកុសល = ចិត្តគិតផ្លូវចំរើន, ផ្លូវល្អ សុខ ។

## យើងត្រូវទុកឲ្យមានអ្វីមួយជាតំណ

គេមិនបង្ខំឲ្យយើងទុករបស់អ្វីអស្ចារ្យ ជាតំណក្រោយយើងទេ ប៉ុន្តែគួរទុករបស់អ្វីមួយ ។ ពាក្យទំនឹមទំនៀមអ្នកឥណ្ឌៀថា: << នរណាបានដាំឈើមួយដើមទុក ហើយទើបស្លាប់ទៅ អ្នកនោះឈ្មោះថាកើតឡើងរស់នៅមិនឥតប្រយោជន៍ក្នុងលោកឡើយ, អ្នកនោះឈ្មោះថាបានបន្ថែមរបស់នៅក្នុងលោក >> ។ ឈើបង្កើតផ្លែផ្កា បើយ៉ាងហោចណាស់ក៏ឲ្យម្លប់ជ្រកដល់មនុស្សដែលកើតខាងក្រោយដែរ ។ ឈើមួយដើម, ផ្ទះមួយ, ប្រដាប់អ្វីមួយ, អាវុធមួយ, សំលៀកមួយ, ឱសថមួយ, សេចក្តីពិត (វិសេស) មួយមាត់, ការរកឃើញដោយវិជ្ជាសាស្ត្រមួយ, សៀវភៅមួយ, រូបប្រតិមាមួយ, ផ្ទាំងគំនូរមួយ របស់ទាំងនេះយើងពល់គ្នាអាចបន្ថែមនៅក្នុងលោកបាន ។

ក្នុងបច្ចុប្បន្ននេះ គ្មាននរណាមិនមានបញ្ញា ហើយមិនដឹងថាជាប់វិទ្យាជាតិដោយមនុស្សស្លាប់ទៅហើយ ដោយមនុស្សក្នុងបច្ចុប្បន្ន នឹង

មនុស្សឯអនាគតឡើយ ។ យើងជាអ្នកទទួលមរតកអំពីជនស្លាប់ទៅ ជនដែលកំពុងរស់នៅ និងទុកមរតកឲ្យជនដែលនឹងកើតឡើងក្នុងខាង-មុខ ៗ ដើម្បីនឹងតបស្នងសងគុណដល់ពួកខ្សែជាតិជនច្រើនពាន់ ដែលបានចំរើនយើងបន្តិចៗឡើងនោះ យើងត្រូវកែជាតិមនុស្សយើងនូវខ្លួន-យើងនឹងមនុស្សនៅជុំវិញយើង ។ យើងជាមនុស្សគ្រាន់បើហើយ-សប្បាយជាងមនុស្សជាន់មុន ចូរយើងធ្វើជនឯក្រោយយើងឲ្យល្អហើយឲ្យសប្បាយលើសយើងទៀត ។ គ្មានមនុស្សណាមួយដែលខ្វះធម៌គឺកុ-សល និងអកុសល ហើយអាចមិនទទួលសេចក្ដីចំរើនក្នុងការៈនៃយថា-កម្មរបស់ខ្លួននោះឡើយ ។

## ពាក្យពន្យល់

ឱសថ = ថ្នាំកែរោគ ។ សេចក្ដីពិត = ការរកឃើញរបស់កំបាំង, ដូចជា-ការបង្កើតអ្វីមួយ ហើយការនោះទៅជារបស់ប្រើប្រាស់បាន ។ ប្រតិមា = រូបសិតឬឆ្លាក់ ។

ខ្សែជាតិ = តំណមនុស្ស ។ មរតក ឬមត៌ក = តំណសំបាច់នៃទ្រព្យមនុស្សស្លាប់ទៅ ។ យថាកម្ម = ប្រាថ្នាពីមុនមក (គឺប្រាថ្នាល្អ ឬអាក្រក់, ប្រាថ្នាល្អបានល្អអាក្រក់ បានអាក្រក់) ។

ពាក្យចោទសួរ

ហេតុអ្វីបានជាអ្នកប្រទេសតណ្ហៀវរាប់អានមនុស្សណាដែលបាន ទុកកេរ្តិ៍អ្វីមួយឲ្យគេឯក្រោយ ។

---

# មធ្យមដ្ឋានទី២

## សេចក្តីខុសឆ្គងបន្តិចបន្តួច

ចូរយើងកុំមើលងាយសេចក្តីខុសឆ្គងបន្តិចបន្តួច ៗ កំហុសបន្តិចបន្តួចនោះមិនជាអ្វីទេ តែបើទុកយូរទៅមិនអាចធ្វើឲ្យវិនាសបានឡើយ ។ ព្រោះចាប់ហូតដល់ធុងដែកដែលជ្រលក់ទឹកក្រឡៃយ៉ាងចំណាប់ ៗ ខ្យងសោកបានធ្វើឲ្យប្រទេសហុល្លង់មានភ័យម្តងហើយ ដោយបោះថ្នល់បន្ទាយទឹក ដែលជាការមាំបំផុតក្នុងលោក ។ សេចក្តីឆ្គាំឆ្គងសឹងជាដើមអាទិ៍នៃកំហុសផកាប ៗ អំពើពុតពាលនោះឯងដែរ ក៏ជាកូននៃសេចក្តីឆ្គាំឆ្គង ។ ចំណុចខ្មៅតូចកើតលើធ្មេញមួយរ៉ាមិនធ្វើទុក្ខអ្វីទេ តែបើអ្នកមិនឲ្យពេទ្យមើល ធ្មេញអ្នកនឹងខូចទាំងមូលពុំលែង ហើយបើអ្នកមិនឲ្យដកយកចេញ ធ្មេញឯទៀតនឹងខូចតាមគ្នាទាំងអស់ ។

សេចក្ដីឆ្មើងក្លាយទៅជាអំពើឆ្គាំឆ្គង ។ អំពើឆ្គាំឆ្គងនោះមិនតូចតាចណាស់ទេ ព្រោះអំពើនោះលាក់ទុកកំហុស ។ កាលណាអ្នកធ្វើខុសអ្វីមួយ ហើយអ្នកមិនហ៊ានប្រាប់គេ នោះតើនរណាលាក់ទុក គឺសេចក្ដីឆ្មើងនោះឯង ។ កុហកជាបុត្រដិតដិតរបស់ក្ដីឆ្មើង តែក្ដីឆ្មើងនោះពុំមែនមានតែកូនមួយប៉ុណ្ណោះឡើយ ។ តាមដោយពិចារណា ខ្ញុំឃើញមានកូនពីរអាក្រក់ដូចគ្នា គឺ ឥស្សាមួយ នឹងឈ្នានីសមួយ ទាំងពីរនេះកើតទៅជាគំនុំ គុំគួន ដែលជាមេនៃគរុទោស ។

ចូរអ្នកមានអធ្យាស្រ័យដល់កំហុសបន្តិចបន្តួចរបស់មិត្តសំឡាញ់អ្នក បើអ្នករំពុកពុំបានតែកំហុសចំពោះខ្លួនអ្នកវិញ ចូរអ្នកប្រឹងដំនះលុះតែឈ្នះ ។

## ពាក្យពន្យល់

ឆ្គាំឆ្គង= មិនប្រព្រឹត្តកិច្ចប្រតិបត្តិតូចតាច ដូចជាពុំបានបើកមួកទឹងគ្រូជាដើម ។ ច្រែះ= គឺស្នឹមដែលកើតលើដែក ។ ឆ្មើង = គឺសេចក្ដីមើលងាយថាគេទាបជាងខ្លួន គឺខ្វះការគោរពតាមសគារៈខ្ពស់ទាប ។ ឥស្សា = ចិត្តខ្ញាញ់នឹងឃើញគេខ្ពស់ជាងខ្លួន ។ ឈ្នានីស – សេចក្ដីប្រឹងប្រែងធ្វើឲ្យគេវិនាសទៅ ។

គរុទោស= ទោសធ្ងន់ គឺ ១ក្រិដ្ឋៈ មជ្ឈិមទោស=ទោសយ៉ាងកណ្ដាល; លហុទោស= ទោសល្មើសបន្ដិចបន្ដួច ។ ទោសលោកសន្មតហៅថា អាជ្ញា ។

# មណ្ឌិមដ្ឋានទី ១

## រៀនមើល - សរសេរតាមសូត្រ

### និយាយអំពីជំនួញ

នៅប្រទេសខ្មែរ របរជំនួញធ្លាក់ទៅលើជនជាតិចិនស្ទើរតែទាំងអស់ ។ ចិនប្រសប់ធ្វើជំនួញណាស់ ចិនមៅទំនិញយកដើម្បីទីងលក់ទៅវិញឲ្យបានថ្លៃច្រើន ។

មានអ្នកជំនួញជាតិចិននៅគ្រប់កន្លែង តាំងពីទីក្រុងរហូតទៅដល់ភូមិតូចៗនៅស្រុកស្រែចំការ ។ គេឃើញចិនរកស៊ីធ្វើជំនួញគ្រប់មុខ ខ្លះជាអ្នកជំនួញស្រូវ ពោត - ម្រេច - គ្រឿងញៀន - ស្បែក - ស្នែង - ត្រី ខ្លះទៀតមានផ្ទះលក់ទំនិញផ្សេងៗ ខ្លះទៀតជាអ្នកបោកអ៊ុតខោអាវ ខ្លះទៀតជាអ្នក

ទិញហើយលក់របស់ចាស់ៗ ខ្លះទៀត ដាក់ពន្ធលក់របស់ឡាយឡុង ខ្លះទៀត ធ្វើជាងមាស - ជាងឈើ - ជាងកំបោរ - ជាងកាត់ដេរខោអាវ - ជាងដេរស្បែកជើង ខ្លះទៀត ជាអ្នកម៉ៅការសង់ផ្ទះធ្វើស្ពាន - លើកថ្នល់ៗលៗ ចិនប្រវ័ញ្ចខ្មែរយកផលដំណាំដោយឲ្យថ្លៃថោកណាស់ ហើយយកផលដំណាំនោះទៅលក់បានចំណេញច្រើន ៗ

ហេតុនេះគួរតែជនជាតិខ្មែររៀនឲ្យចេះស្គាល់មុខរបរជំនួញ ដើម្បីកុំឲ្យចិនបោកបាន ៗ

ពន្យល់ពាក្យ.- ជំនួញ = មុខការ, របរដែលជួញ, របស់ដែលគេជួញ ។ របរជំនួញ= របរខាងការជួញ ។ ប្រសប់= គុ.ថ្នឹក ប៉ិន, ប៉ិនខាងស្ទង់, លៃ, ត្នេរ ។ ម៉ៅ= កិ. រួបរួមទាំងអស់, ទទួលដោយរួបរួមទាំងស្រុង ។ ប្រវ័ញ្ច= កិ. (ម.ថ: ប្រវាញ់) បញ្ឆោត, បោកប្រាស ។

ពាក្យសួរ.- នៅប្រទេសខ្មែរមានរបរជំនួញច្រើនដែរឬទេ ; របរជំនួញនោះធ្លាប់នៅលើជនជាតិណា ? ខ្មែរចូលចិត្តរកស៊ីធ្វើជំនួញឬទេ ? ព្រោះអ្វី? ហេតុអ្វីបានជាចិនចូលចិត្តធ្វើជំនួញណាស់ ? ព្រោះអ្វីបានជាចិនមានភោគសម្បត្តិច្រើនជាងខ្មែរ ? ខ្មែរយើងត្រូវធ្វើដូចម្ដេចកុំឲ្យចិនបោកបាន? ៗ ពាក្យទំនឹមទំនៀមថា៖ ចេះមកពីរៀន មានមកពីរក ៗ

# អាទិកដ្ឋាន

## បង្រៀនមើល - បង្រៀនពាក្យ

អាទិត្យទី១-

ក្មេងបេះធ្វើឱ្យឪពុកម្ដាយសប្បាយចិត្ត

( សៀវភៅខេមរភាសាអាទិកដ្ឋានទំព័រទី ១ ) ។

នាម – ឪពុក, ក្បាល, សៀវភៅ, ទំព័រ, មេរៀន, សត្វចាប, សំឡេង បង្អួច, ដើមត្របែក, ប្រកផ្ទះ’ រូប, ខ្លែង ។

គុណនាម.– ក្រាស់, ខ្ចី, វែង, ស្ដើង, ពីរោះ, ធំ, ក្រហម, ក្រអូប, ល្អ, ទោរទន់ ។

កិរិយាសព្ទ – ឱនក្បាលចុះ, ចាំមើលមេរៀន, យំសំឡេងពីរោះ ស្ដាប់សំឡេងចាបយំ, លេងរូប, បង្ហើរខ្លែង, ស្រែក, សើច, ធ្វើជាមិនដឹង

ពន្យល់ពាក្យ.– ធ្វេស = ធ្វោយ’ ប្រហែសធ្វេសស្មារតី, ធ្វេសគំនិត ។ វក្សរ = ជិត ។ មិនរវល់ = មិនអើពើ ។ ទោរ = គោង, ទ្រេត ។

ប្រកផ្ទះ = បនោ្ទះផ្ទះ ។ វ្ញ = វត្ថុជាខ្សែរង្វេង ។ ពពេះ = សំឡេង គាប់ត្រចៀកគួរឲ្យចង់ស្តាប់ ។

សូមតម្រូវពាក្យខ្លះក្នុងមេរៀន = ទំពាំ, មិន, គិត ជា ទំពារ, មិនគិត ។

បទវេយ្យាករណ៍.– ប្រាប់, ស្តាប់, ផល់, បង់, បប់, អស់, ( មានសញ្ញាបន្តក់លើស្រៈ អា - អ ) ។

ហាត់ភាសា.– កូនរឿងនេះគេនិយាយពីអ្វី? ចាបជាសត្វដូចម្តេច? ចាបកូនរឿងនេះវាទំនៅឯណា ? ដើមត្របែកនោះនៅឯណា ? មានអ្វីនៅលើដើមត្របែក ? មានអ្វីនៅប្រកបនោ្ទះផ្ទះ ? ចៅជួនមានចិត្តចង់ស្តាប់សំឡេងចាប – បេះត្របែកទុំ – បង្ហើរខ្លែង – លេងរ្វៃដៃរបួទេ ? ព្រោះអ្វី?

## ២– ត្រូវមកសាលារៀនឲ្យទាន់ពេលវេលា

(សៀវភៅដដែលទំព័រទី២) ។

ពាក្យទីងកាសា (សូមធ្វើដូចមេរៀនមុន) ។

## វិធីហាត់សរសេរ

ចូរធ្វើជាឃ្លាទីងពាក្យខាងក្រោមនេះ៖

សាលារៀន – ស្គរ – រៀន – យឺតយូរ ។

ឧទាហរណ៍ – ខ្ញុំទៅសាលារៀនរាល់ថ្ងៃ ។ នៅក្នុងសាលារៀនខ្ញុំមានស្គរមួយ ។ ខ្ញុំខំរៀនឲ្យបានចេះឆាប់ ។ ខ្ញុំប្រឹងដើរឲ្យលឿន ដើម្បីកុំឲ្យទៅដល់សាលារៀនយឺតយូរ ។

– ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖ សិស្សមិនត្រូវមកសាលារៀនឲ្យ..... ពេកឬឲ្យ.... ពេកទេ ។ សិស្សត្រូវមកសាលារៀនឲ្យ...ម៉ោងហើយមិនត្រូវប្រឡែងគ្នាលេង...(នៅកណ្ដាលផ្លូវ)ទេ ។

## សរសេរតាមសូត្រ

សូមជ្រើសយកសេចក្ដីក្នុងមេរៀន ដែលបានបង្រៀនមើលខាងលើនេះចំនួនបួនប្រាំបន្ទាត់មកឲ្យសិស្សសរសេរតាមគ្រូថាផងចុះ ។

## តែងសេចក្ដី ១

ចូរអ្នកអធិប្បាយអំពីសិស្សឧស្សាហ៍រៀនសូត្រណាម្នាក់ ដែលអ្នកបានស្គាល់ពិតប្រាកដ ។

## ទំនងតែង

១- សេចក្ដីផ្ដើម ៖ អ្នកបានស្គាល់សិស្សណាម្នាក់ដែលឧស្សាហ៍រៀនសូត្រឬទេ ? ។

២- សេចក្ដីពប់រៀប ៖ សិស្សនោះឈ្មោះអ្វី? អាយុវាប៉ុន្មានឆ្នាំ? វារៀននៅថ្នាក់ណា? វាចាំមេរៀនឬទេ? វាធ្វើដូចម្ដេចខ្លះនៅសាលារៀន នៅផ្ទះ ? ។

## អក្សរផ្ចង់

ក ភ គ ត ព ធ្លៀ

ភ ភា ភី ភូ ភួ ភើ ភេ ភែ ភោ ភុំ ភុំភឿន

រកភួយ កុំភិតភ័យអី ។

## បង្រៀនពាក្យ-ហាត់ភាសា

## អាទិត្យទី ២ — អំពីក្រុមញាតិ

នាម. — ឪពុក (បិតា), ម្ដាយ (មាតា), កូន, បង, ប្អូន, កូនច្បង, កូនបន្ទាប់, កូនពៅ, កូនខ្ចី, កូនប្រុស, កូនស្រី, រៀមច្បង, ក្រុមញាតិ, ញាតិសន្ដាន ។

គុណនាម.— ក្មេង, ចាស់ តូច, ធំ, កំឡោះ, ក្រមុំ, ជំទង់ ។

កិរិយាសព្ទ.— កើតកូន, សម្រាលកូន, ឆ្លងទន្លេ, ប្រសូត, ថែទាំ, បីបាច់រក្សា, ចិញ្ចឹមកូន, បំបៅកូន, ផ្តេកកូន, ផ្តួតទឹក, បញ្ចុកបាយ, ពប្អូន

ហាត់ភាសា.— ក្រុមញាតិអ្នកមានមនុស្សប៉ុន្មាននាក់ ? មាតា--បិតាអ្នកអាយុប៉ុន្មានឆ្នាំហើយ ? អ្នកមានបងប្អូនប៉ុន្មាននាក់ ? ប្រុសប៉ុន្មាន ស្រីប៉ុន្មាន ? — អ្នកណាជាកូនច្បង ? កូនពៅឪពុកម្តាយអ្នកប្រុសឬស្រី ? យ៉ាងដូចម្តេចដែលហៅថាកូនកំឡោះ ? កូនក្រមុំ ? — កូនជំទង់ ? កាលណាប្អូនអ្នកយំ អ្នកធ្វើដូចម្តេច ? ម្តាយអ្នកធ្វើដូចម្តេច ? ហេតុអ្វីបានជាឪពុកម្តាយអ្នកទៅធ្វើការរាល់ថ្ងៃ ? — តើអ្នកស្រឡាញ់ឪពុកម្តាយអ្នក — បងប្អូនអ្នកឬទេ ? វិធីហាត់សរសេរ .— សូមយកពាក្យចោទសួរ ៣ ឃ្លា ខាងលើនេះមកដាក់ឲ្យសិស្សឆ្លើយផងចុះ ។

## បង្រៀនមើល

១— អំពីនៅជួបជុំក្រុមញាតិក្នុងវេលាយប់

( សៀវភៅវិជ្ជាខេមរភាសាបរិវច្ឆណដ្ឋាន ទំព័រ ៤៦ )

២– សេចក្ដីស្នេហានឹងបងប្អូនបង្កើត

( សៀវភៅវិជ្ជាខេមរភាសាអាទិកដ្ឋាន ទំព័រ ៩ )

ពន្យល់ពាក្យក្នុងមេរៀនទី ១ – អាស្រ័យ = ស៊ី, ទទួលទាន, បរិភោគ ព្យួរនៅពិតាន ( ម.ថ. ពិដាន ) ថ្ពក់នៅរបាំងក្រោមដំបូល ។ ដេញចាប៉ី = កេះ, គ្រេះខ្សែដទ្រ្ទី ។ និទានរឿងព្រេង = និយាយ ឬ សំដែងរឿងដែលជាយូរអង្វែងហើយ ។

– ក្នុងមេរៀនទី ២ – ជំម្ងឺ = សេចក្ដីឈឺចាប់, អាពាធរោគ ។ ដណ្ដាំបបរ = ចំអិនបបរ ។ ផ្កាភ្លើង = កំទេចភ្លើងដែលចេញឬព្រាយចេញព្រោងព្រាត ។ បាវព្រាវ = មនុស្សអ្នកខ្សត់ខ្សោយទន់ទាបឥតមានទីពំនាក់ដែលចូលមកជ្រកអាស្រ័យនៅផង, ជាអ្នកធ្វើកិច្ចបំរើដូចបាវៗ

## សរសេរតាមសូត្រ

សៀវភៅដដែលទំព័រ ៩ តាំងពីបន្ទាត់ទី ១ រហូតដល់ ...

ហេតុអ្វីបាជាប្អូនទៅធ្វើឲ្យទៀយលំបាកខ្លួនឯងយ៉ាងដូច្នេះ ខ្ញុំអ៊ីបាវព្រាវនៅក្នុងផ្ទះ ។

ពាក្យពិបាក.– ស្នេហា (ស្នែហា) – ប្អូន (បដើងអ) បង្កើត (ព្យាង្គតម្រួត) ជម្ងឺ (ម ជំនួសនិគ្គហិត "ំ")

បបរ (រ) – ហើរ (រ) – ក៏ (៏) ។

បទវេយ្យាករណ៍ – សញ្ញាបន្តក់ ( ់ ) ប្រើតែលើពាក្យដែលកើតពីស្រៈ អ អា ហើយស័ព្ទខ្លី ។

ឧទាហរណ៍ – ដល់, ម្នាក់, ចាស់, ស្រឡាញ់, ណាស់, ស្រាប់ៗ

អក្សរដែលទទួលបន្តក់បាន៖ ក ង ច ញ ត ន ប ល ស ។

## តែងសេចក្ដី ១

នៅក្នុងខែដំបូង គ្រូបង្រៀនសិស្សឲ្យចេះរកទំនងតែង ឲ្យតែងតាមមើលសង្កេតរូបគំនូរ ។

### អំពីនៅជួបជុំក្រុមញាតិក្នុងវេលាយប់

(សៀវភៅវិជ្ជាខេមរភាសាបរិច្ចណដ្ឋានទំព័រ ៤៧) ។

ទំនងតែង

១– សេចក្ដីផ្ដើម.– ក្នុងរូបភាពនេះមានមនុស្សប៉ុន្មាននាក់? ហើយមានអ្វីខ្លះនៅពីលើ – មនុស្សទាំងអស់នេះគឺអ្វី?

....

២– សេចក្ដីកប់រៀប.– នៅចុងតុខាងស្ដាំមានអ្វី – ស្លៀកពាក់ដូចម្ដេច – អង្គុយលើអ្វី – ធ្វើអ្វី ?· អ្នកណាអង្គុយនៅខាងឆ្វេងតុ – ធ្វើអ្វី ? – ធ្វើដៃដូចម្ដេច – ហើយនៅខាងមុខមានអ្នកណាខ្លះឈរ – ធ្វើអ្វី ? – នៅបន្ទាប់ហើយខាងស្ដាំដៃមានអ្នកណាឈរឬអង្គុយ – ម្ដាយកំពុងធ្វើអ្វី – ហើយនៅខាងចុងបំផុតមានអ្នកណា – អង្គុយធ្វើអ្វី ?

៣– សេចក្ដីបញ្ចប់.– យោបល់ – អ្នកយល់ឃើញដូចម្ដេចអំពីគ្រួសារនេះ ? – ព្រោះអ្វី ។

## អាទិត្យទី ៣

### បង្រៀនមើល – បង្រៀនពាក្យ – ហាត់ភាសា

១– កូនលុះដោយដំបូន្មាន មាតាបិតា

(សៀវភៅវិជ្ជាខេមរភាសាអាទិកថ្នាន ទំព័រ ៣២) ។

២– វត្តប្រតិបត្តិប្រសើររបស់កូន

(សៀវភៅដដែល ទំព័រ ៣៨) ។

៣– បងប្អូនល្អ (សៀវភៅដដែលទំព័រ ៤៤) ។

ពន្យល់ពាក្យក្នុងមេរៀន ទី ១ .– លុះដំបូន្មាន = ធ្វើតាមពាក្យប្រដៅ (ស្ដាប់ដំបូន្មាន) – ម្នីម្នា = រវៀសរវៃ – រួតរះ - រួសរាន់ប្រញាប់ប្រញាល់ ។

ពន្យល់ពាក្យក្នុងមេរៀនទី ២ .– ដង្កាយព្យុះ = ធ្នូពពក សរវែងលាយ ធ្នូកជាមួយទឹងពពកឯទេត ។

ថែចាំ = ថែដោយប្រយ័ត្ន មិនប្រហែសធ្វេស (ថែញឹកញយ) ។

ធុញថប់ = ទញ់ទាល់ក្នុងចិត្ត, ជិនឆ្អន់ ហើយណាយរសាយចិត្ត ។

ប្រតិបត្តិឬបដិបត្តិ = ការប្រព្រឹត្ត កាន់ : ធ្វើតាមច្បាប់ ។

វិធីហាត់សរសេរ .–

ចូររកវេវចន : នឹងពាក្យ ៖ ឃាវព្រាវ – ព្យាយាម · ម្នីម្នា ។ ចូររកពាក្យផ្ទុយនឹងពាក្យ ៖ ស្រឡាញ់ – សប្បាយចិត្ត - ចំនៀមហាត់ភាសានិងហាត់និយាយ (សូមធ្វើដូចអាទិត្យមុន)

សរសេរតាមសូត្រ

សូមយកសេចក្ដីបង្រៀនមើលខាងលើនេះ មកដាក់ឲ្យសិស្ស សរសេរតាមគ្រូថាផង (សូមធ្វើដូចអាទិត្យមុន)។

អក្សរផ្ចង់

ក ភ គ ត ឥ ត្តៀ

ត តា តី តូ តួ តេ តឿ តែ តោ តៅ តុំ តំ តុ តុះ

តុំកំបោរ តាតូបតែងតួ វែកតោក

# កុមារដ្ឋាន

រៀនពាក្យនឹងភាសា

អាទិត្យទី ១.-

សាលារៀន

នាម–. សាលា, ផ្ទះ, បន្ទប់, ថ្នាក់, កុមារដ្ឋាន, បរិច្ឆណដ្ឋាន, អាទិកដ្ឋាន, មជ្ឈិមដ្ឋាន, ឧត្តមដ្ឋាន ។

គុណនាម.— ល្អ, ធំ, ទូលាយ, ស្អាត, ស្ដុកស្ដម្ភ, ថ្មី, ត្រជាក់, រហើយ ៗ

កិរិយា.— រៀន, សូត្រ, ទន្ទេញ, លេង, ហ៊ោ, ស្រែក ៗ

ភាសា.— អ្នកបានរៀនក្នុងសាលាប៉ុន្មានឆ្នាំហើយ? ពីឆ្នាំទៅអ្នកបានរៀននៅថ្នាក់ណា? ចុះឆ្នាំនេះអ្នករៀនថ្នាក់អ្វី? អ្នកស្គាល់ថ្នាក់អ្វីខ្លះ? សាលាដែលអ្នករៀននេះតើមានសភាពដូចម្ដេចខ្លះ? ៗ

## អាទិត្យទី ២–.

## គ្រឿងប្រដាប់នៃសាលានិងគេហដ្ឋាន

នាម.— ផ្ទះបាយឬរោងចុងភៅ, បង្គន់, ទឹក, ប្រដាប់ហាត់ប្រាណ, ស្គរ, ប្រដាប់សំរាប់ថែទាំសាលា, ផ្ទះដេក, ផ្ទះចានហ្វាន ៗ

របស់នៅក្នុងថ្នាក់រៀន.— តុ, ទូ, តុគ្រូ, កៅអី, ដីសម៉ា, ក្ដារខៀន, ផែនទី, ប្រក្រតីទិន, ផ្ទាំង, គំរូ, នាឡិកា ឬ នាលិកា ៗ

គុណនាម.— តូច, ចាស់, ធុះធាយ, ស្អាត, ស្អុយ, ជ្រៅ, ភ្លារ, មាំចំណាប់, ធំ, ធូរ, តឹង, ស្រួល, ល្អ, រលោង, រហែក, ថ្មី ៗ

កិរិយា.- បរិភោគ, អាស្រ័យដំណេក, ដឹក, ត្រង់, រត់, លោត, ផ្ដោះ, ហាត់, វាយ, ដេក, ត្រួតត្រា, រៀប, ឆ្នូត, ដុស, ព្យួរ, លុប, មើល, គិត, វាយម៉ោង, បង្អុល, ថែទាំ, បោស, ប្រាស់ ។

## អាទិត្យទី ៣.–

## បន្ទប់រៀននឹងរបស់ក្នុងថ្នាក់រៀន

នាម.– បន្ទប់រៀន ថ្នាក់ កន្លែង ជើងថ្កល់ ថតតុ ជើងតុ ខ្នងតុ ត្របៀកសោ កូនសោ ខ្នង់បែកពេលរៀន ប្រកាសបញ្ញត្តិ សាលា ដីស ជួរតុ បន្ទោះតុ បាតតុ ៗ ទ្វារ បង្អួច ជញ្ជាំង ដំបូល ពិតាន កំរាលក្ដារ ៗ

គុណនាម.– ស្អាត ទូលាយ ស្រឡះ ងងឹត រហើយ បួនជ្រុង វែង ខ្ពស់ ក្រឡឹង ខូច ប្រេះ ខ្មៅ ថ្មី រេច បាក់ ផុយ ស្រស់ ស្រឡះ ត្រង់ ជ្រេ រៀប ៗ

កិរិយា.– បិទទ្វារ បង្អួច ដាក់រនាំង ប្រក់ដំបូល ជូតក្ដារ បោសជញ្ជាំង ដាក់ទ្វារបង្អួច ដុសក្ដារ បោសកំរាល ខាត់ ដុស ជូត លុប សរសេរ ចាក់សោ បើក ព្យួរ ភ្ជាប់ បិទ រៀប ដំរង់ អង្គុយ ឈរ ៗ

## អាទិត្យទី ៤ -.

### មនុស្សទៅក្នុងថ្នាក់

ពាក្យ .- កូនសិស្ស, គ្រូ, កុមារ, កុមារី, កូនសិស្សប្រុស, កូនសិស្សស្រី, គ្រូប្រុស, គ្រូស្រី, ចាងហ្វាងសាលា ។

គ្រូធំ, ចាស់, ក្មេង, តូច, ធំ, ជំទង់, រពិស, កាច, ស្លូត, ខ្ជិល, ឧស្សាហ៍, តក់ម៉ក់, ព្រហើន ។

រៀន, ទន្ទេញ, សរសេរ គូរ, អានពាក្យ, មើល, បំឡង, ស្ដាប់ ស្រែក ។

## រៀនមើលសរសេរ

### អាទិត្យទី ១

សុំបង្រៀនមេរៀនទី ៣ ( ព្យញ្ជនៈ ផ្សំនឹងស្រៈ ក ។

ខ្ញុំបានជំរាបហើយក្នុងខែមុនថា ការបង្រៀនក្មេងជម្បូងគ្មានក្បួនឯណាជាពិតទេឡើយ ស្រេចនូវលោកគ្រូធ្វើដូចម្ដេចក៏ដោយឲ្យតែក្មេងចេះចាំអក្សរ បែបម៉្យាងគ្រូបង្ហាញអក្សរ ក ផ្សំនឹង អ; អា កា; អិ កិ; អើ កើ....

ក្នុងអក្សរ ក បំបែកនោះគួរតែឲ្យរៀនឲ្យស្ទាត់កុំប្រញាប់នឹងបង្រៀនតួឯទៀត ទោះ ៥ ឬ ៦ ថ្ងៃក៏បាន ។ បើចេះ ក ហើយឲ្យបង្រៀន ៖ ព្រោះជាអឃោសៈដូចគ្នា ។

## អាទិត្យទី ២

សុំសាបង្រៀនមេរៀនទី ៣, ៤ ហើយនឹងបង្រៀនមេរៀនទី ៥ (ក្នុងសៀវភៅកុមារដ្ឋាន)

## អាទិត្យទី៣

សុំបង្រៀនមេរៀនទី ៥ ទំព័រទី ៨ សៀវភៅដដែល

## អាទិត្យទី ៤

សុំសាបង្រៀនឡើងវិញមេរៀនដែលបានរៀនពីអាទិត្យមុនៗមក ។

# បរិច្ឆណដ្ឋាន

## រៀនពាក្យ – ហាត់ភាសា

### អំពីសត្វ

នាម ឆ្កែ ឆ្មា ក្ងាន ទា សត្វមាន់ មាន់បារាំង ព្រាប គោ ក្របី

សេះ ដំរី ពពែ ចៀម លា អូដ្ឋ ជ្រូក សេះទេស គោសៀម គោខ្មែរ គោជ្រលែង ។

គុណនាម សាហាវ កាច ស្លូត ស្លាក់, សាំង មាំ ខ្លាំង ធាត់ ស្គម យឺត, រហ័ស, លឿន, សម្បើម, ស្រាវ កន្ទ្រល សំទក់ ចង្រ្គង. គំប៉ោង សំដឹត ។

កិរិយា ព្រុស, បណ្ដេញ, ចាប់, ខាំ, បំផ្លាញ ហួរ, ហែល, រោរ, ពង, ប្រាស់, ការពារ, ទឹម, ដឹក, អូស ដិះ កាត់, គ្រៀវ បង្កាត់, ថៃ, ចិញ្ចឹម, លក់, ទិញ ។ ភាសា នឹងបង្រៀននាមសុំឲ្យគ្រូប្រាប់ឈ្មោះសត្វ ដោយគំនូរឬដោយរូបមែនៗ នឹងបង្រៀនគុណនាមឲ្យចោទសួរថាសត្វនោះដូចម្ដេច នឹងបង្រៀនកិរិយាឲ្យចោទសួរថាសត្វនោះៗ ធ្វើអ្វីខ្លះ បង្រៀនបណ្ដើរកត់ពាក្យបណ្ដើរនៅលើក្ដារខៀនរួចស្រេចហើយទើបចោទសួរដូចមានគំរូខាងក្រោមនេះ ។

អ្នកមានឆ្កែឬទេ ? អ្នកមានឆ្មា ក្ងាន ទា មាន់បារាំង ព្រាប ? ឆ្មាអ្នកចាំធ្វើអ្វីឲ្យអ្នក ? គេចិញ្ចឹមឆ្កែធ្វើអ្វី ? ក្ងាននឹងទាមានរូបរាងដូចគ្នាឬទេ មាន់នឹងមាន់បារាំង ? ។

## អាទិត្យទី ២.-

### អំពីសត្វ (ត)

នាម៖— ស្វា, ទន្សាយ, ខ្លា, ចចក, សំពោច, ប្រើសក្តាន់, រមាំង, ឈ្លូស, ទន្សោង, ខ្ទីង, រមាស, ខ្លាឃ្មុំ, ទោច, ស្វាក្រេះ, ស្វាព្រាហ្មណ៍, ពស់, អណ្តើក, កុក, ត្មាត, អក, ខ្លែង, ប្រមង់, ទុង, ក្អែក, ក្អែកទឹក, ស្មោញ, ក្រសារ ។

គុណនាម៖— ផ្លាង, រហ៊ុលរហ៊ូច, ស្វាហាប់, កាំកាវ, ល្វតល្វៃ, កំព្រឹង, កណ្តុកន្តុញ, ខ្មៅ, ប្រផេះ, គគ្រាត, គគ្រើម ។

កិរិយា៖— លោត, គ្រហឹម, លូ, ថ្ពូប, លូន, វារ, ហើរ, ត្រដាង, ចោះពួយ, ឆាប, បណ្តែត, ឆក់, មុជ, ចឹក, ព្រេច, ហែល, ស៊ីស្មៅ, បេះបោច ។

## អាទិត្យទី ៣.—

### រុក្ខជាតិ

នាម៖— ស្វាយ, ខ្នុរ, ដូង, ល្វា, ទៀប, ត្របែក, ត្នោត, ជ្រៃ, គគីរ, ផ្ចឹក, សុក្រំ, គ្រញូង, នាងនួន, បេង, ឈើទាល, ក្រាច, ខ្លុង, ត្បែង,

គុណនាម.– ត្រសុំ, សាខា, ប្រួង, ធ្ងារ, រីង, ជាប់, ផុយ, វែង, ស្រួយ, ពុករលួយ, ស្រស់, ខៀវ, ស្រពោន, ស្វិត, ក្រៀម, ស្រក់រីក សាញស្ងួត ។

កិរិយា.– ដាំ ឡើង ដុះ រំលំ បេះ ការបំបែក កាត់ ពុះ ទល់ ទ្រ បេះ លើក គាស រុស ក្តិត បណ្ដុះ រះ មែក ជ្រុះ ស្ទឹក រលើង លូត ។

អាទិត្យទី ៤.–

សុំសាបច្រៀនឡើងវិញ ពាក្យដែលបានរៀនពីអាទិត្យមុនៗមក

## រៀនមើល

អាទិត្យទី ១.–

ក្របី (សៀវភៅបរិវេដ្ឋ ទំព័រ ១១៥

ពាក្យពន្យល់ វាមិនស្វាមានរោមច្រើន (រោមមិនលុបស្បែកដូចគោ) ដំណើរតើត (ដើរហើយងើបក្បាល) ចិត្តធូន់(មានកំណាត់)

ពាក្យចោទសួរ.– ក្របីមានរូបរាងប្លែកពីគោដូចម្ដេច ? ក្របីវាចូល

ចិត្តហាលថ្ងៃដូចគោឬទេ ? ព្រោះអ្វី ? (ព្រោះស្បែកខ្មៅ ហើយពុំសូវមានរោម, ពណ៌ខ្មៅស្រូបកំដៅ) ក្របីបំរើមនុស្សដូចម្ដេច ? កាលណាវាស្លាប់ទៅគាត់បំណែកខ្លួនវាមានប្រយោជន៍ខ្លះដែរឬទេ ? គេធ្វើទីងពីស្នែងក្របី និងស្បែកក្របី :

អាទិត្យទី ២.–

១– សត្វស្លាបមានប្រយោជន៍ដល់អ្នកធ្វើស្រែ

(សៀវភៅបរិច្ចទំព័រ ៥៣)

២- ឃ្មុំ (សៀវភៅដដែលទំព័រ ៤០)

អាទិត្យទី ៣.–

សារិកាកែវ (សៀវភៅដដែលទំព័រ ៥១)

អាទិត្យទី ៤.–

១– អំពីកណ្ដុរ (សៀវភៅដដែលទំព័រ ៥២)

២– អ្នកគង្វាលក្របី (សៀវភៅដដែលទំព័រ ២៤)

ស៊ុបគ្រៀនពីអាទិត្យទី ១

## សរសេរតាមសូត្រ

វិធីធ្វើមេរៀននេះយើងទុកឲ្យលោកគ្រូជ្រើសរើសមេរៀនណាដែលបានមើលរូបហើយនៅក្នុងមេរៀនមើលយកមកសរសេរតាមសូត្រឲ្យសិស្សដើម្បីនឹងបញ្ញាត់ពាក្យពិបាកដែលសិស្សបានឃើញរួចមកហើយ ។

## តែងសេចក្ដី

ចូរបំពេញចន្លោះដោយពាក្យគួរប្រើ

ក្នុងភូមិខ្ញុំគេប្រើក្របីសំរាប់អូសរទេះនឹងទឹមនង្គ័ល ។ ក្របីមានខ្លួនវា ..... វាមានកម្លាំងច្រើនជាង . . . ។ ស្នែងវា . . . ហើយ · · · ទៅក្រោយ ។ ក្របីជាសត្វ . . . ស្មៅបន្តិចបន្តួចក៏វាស៊ីឆ្អែត ។ វាចូលចិត្ត . . . ព្រោះវា . . . ។ គេយកស្នែងវាធ្វើជា . . . ។

សុំឲ្យតែងសេចក្ដីទុកចន្លោះដូចរបៀបមុនអំពីគោ, ដំរី, ខ្លា ។

# មធ្យមដ្ឋានទី ២ និង ឧត្តមដ្ឋាន

## នព្វន្ត

### អាទិត្យទី ១ _ . អំពីចំនួនទសភាគ ។

យើងបានឃើញថាគេចែកម៉ែត្រជាភាគ ១០ ស្មើគ្នា មួយភាគ ៗ ហៅថា១ដេស៊ីម៉ែត្រ ( ឯលីត្រក៏ចែកជា ១០ ភាគដូចគ្នាដែរ ) ដូច្នេះ មួយដេស៊ីម៉ែត្រគឺជាខ្នាតមួយក្នុងភាគ ១០ នៃម៉ែត្រ ដេស៊ីម៉ែត្រជារង្វាស់ មួយក្នុងភាគ ១០ នៃលីត្រ ។

បើយើងយកនំមួយមកចែកជា ១០ ចំណែក ចំណែកនីមួយៗ ហៅថា ១ ក្នុងភាគ ១០ នៃ ១ គត់ ។

១ គត់ = ១០ ទសភាគ

មួយដេស៊ីម៉ែត្រ ( ១ ដ.ម. ឬ ០ មុ ១ ) មួយដេស៊ីលីត្រ ( ០លុ១ គឺជាចំនួនទសភាគ ។

អំពីមើលចំនួនទសភាគ ត្រូវមើលចំនួនគត់មុនរួចមើលចំនួនទសភាគទៀត ។ បើចំនួនទសភាគនោះជាម៉ែត្រ ជាលីត្រ ឬ ជាក្រាមត្រូវមើលថា

៧ម៉.៥ ( ប្រាំពីរម៉ែត្រ ៥ ដេស៊ីម៉ែត្រ )

៧លី.៥ ( ប្រាំពីរលីត្រ ៥ ដេស៊ីលីត្រ )

០ក្រ.៨ ( សូន្យក្រាម ប្រាំបីដេស៊ីក្រាម )

អំពីសរសេរចំនួនទសភាគ ។ ត្រូវសរសេរចំនួនទសភាគនៅខាងស្តាំចំនួនគត់តែត្រូវកុំភ្លេចដាក់កណ្ដកសញ្ញាខណ្ឌចំនួនទាំងពីរនេះ

ឧបមា ៧ គត់ ៥ ក្នុងភាគ ១០ នៃ ១ គត់ត្រូវសរសេរ ៧,៥ ។ សូន្យគត់ ៨ ក្នុងភាគ ១០ នៃ ១ គត់ត្រូវសរសេរ ០,៨ ។ល។

អំពីលេខគុណដែលមានចំនួនគត់ ។

ឧបមា អង្ករមួយតៅថ្លៃ ៣២ រៀល តើអង្ករ ៥ តៅថ្លៃប៉ុន្មាន ? ដើម្បីរកថ្លៃអង្ករទាំងអស់ឲ្យឃើញនោះតោងផ្សំថ្លៃអង្ករ ១ តៅឯង ១ តៅ ទាល់តែគ្រប់ ៥ ដង ។

គឺ ៣២៛ + ៣២៛ + ៣២៛ + ៣២៛ + ៣២ = ១៦០៛

ធ្វើបែបនេះវែងពេក ដើម្បីជៀសវាងធ្វើលេខបូកមានចំនួនដដែលៗដូចខាងលើនេះ គេធ្វើលេខគុណវិញ គឺអង្ករ ៥ តៅថ្លៃ៣២រៀល ៥ដង ឬ ១៦០ រៀល ។ ដូច្នេះលេខគុណជាលេខដែលគេត្រូវធ្វើចំនួនណាមួយឲ្យទៅជាច្រើនដង ។ សៀវភៅ ១ ថ្លៃ ៣ រៀល សៀវភៅ ៤ ថ្លៃប៉ុន្មាន

ធ្វើលេខគុណយ៉ាងដូចម្តេច ? គឺលេខគុណនីមួយៗមានចំនួនតាំង ១ នឹងមេគុណ ១ ។

៣៥ ចំនួនតាំង
× ៤ មេគុណ
―――
១៤០ ល័ព្ធ

ចំនួនដែលគេត្រូវធ្វើហៅថាចំនួនតាំង ឯចំនួនដែលសម្រាប់ធ្វើជាប៉ុន្មានដងៗនោះ ហៅថាមេគុណ ។ ឯសញ្ញាខ្វែងបញ្ឈៀង ( × ) ហៅថាគុណ ។ ១៤០ នេះជាល័ព្ធ

ខ្ញុំត្រូវសរសេរចំនួនតាំង (៣៥) ខាងលើ ចំនួនមេគុណ (៤) ខាងក្រោមខ្ទង់រាយចំនួនតាំង រួចខ្ញុំគូសបន្ទាត់ផ្តេក ១ ខាងក្រោមទៀត ហើយខ្ញុំចាប់ធ្វើលេខពីស្តាំទៅឆ្វេង ខ្ញុំថា ៤ ប្រាំដងត្រូវជា ២០ ខ្ញុំសរសេរលេខសូន្យ (០) ក្រោមបន្ទាត់ផ្តេកត្រង់ខ្ទង់រាយ ទុក ២ ផ្ញើនឹងខ្ទង់ដប់ រួចហើយហៅតទៅទៀត ៤ បីដងត្រូវជា ១២ នឹង ២ ជា ១៤ ខ្ញុំសរសេរលេខ ១៤ នៅក្រោមខ្ទង់ដប់ តាំងអស់បាន ១៤០ ។

— អំពីចំនួនតាំងនឹងមេគុណមានលេខតែមួយខ្ទង់ ។ នឹងធ្វើលេខគុណដែលមានចំនួនតាំងនឹងមេគុណតែមួយខ្ទង់ គេគ្រាន់តែប្រើមេលេខគុណបានហើយ

ដូចជា ៩ × ៥ = ៤៥

ដូច្នេះសិស្សត្រូវរៀនមេលេខគុណឲ្យចាំស្ទាត់មែនទែន

ការហាត់.– សុំគ្រូរកលេខគុណដាក់ឲ្យសិស្ស ធ្វើនៅក្ដារខៀនផងចុះ ។

បំណោទ.– ក្នុងខែមេសាឆ្នាំ ១៩៥០ មានថ្ងៃអាទិត្យ ៥ ដង ថ្ងៃឈប់ចូលឆ្នាំ ៣ ថ្ងៃ ដែលគូលីម្នាក់ស៊ី ១៥ រៀល ក្នុងមួយថ្ងៃមិនបានធ្វើការ ។ តើគូលីនេះសន្សំបានប្រាក់ទុកបានប៉ុន្មានរៀលក្នុងខែមេសានេះ បើគេដឹងថាក្នុង ១ ថ្ងៃវាចាយអស់ ១១ រៀល ។

អាទិត្យទី ២ .– លេខគុណ (ត)

របៀប.– មេគុណជាចំនួនមានសូន្យនៅខាងចុង ។ ដូចជា ៤៣ × ៣០ = នេះត្រូវយក ៤៣ គុណនឹង ៣ រួចគុណនឹង ១០ ទៀត ។ បើមេគុណមានសូន្យ ២ នៅខាងចុងត្រូវគុណនឹង ១០០ ទៀត បើមេគុណមានសូន្យ ៣ ត្រូវគុណនឹង ១០០០ ។ ដូច្នេះ ៤៣ × ៣០០ = ១២៩០០ ។

ការហាត់.– ចូរធ្វើលេខខាងក្រោមនេះ:

| | |
|---|---|
| ៦៣៨ × ៣២៦ = | ៩០៨៤ × ៧៦០០ = |
| ៤៧២៥ × ៩៤០ = | ៧០២៦ × ៣.០០៩ = |

ចំណោទ ។- សៀវភៅមើលមួយមានទំព័រ ១៨៧ ក្នុង ១ ទំព័រ មាន ៤៣ បន្ទាត់ ហើយក្នុង ១ បន្ទាត់ មានអក្សរ ៥៧ តួ តើសៀវភៅនោះមានអក្សរៈប៉ុន្មានតួ ។

## អាទិត្យទី ៣ ។- លេខចែកមានចំនួនគត់ ។

ខ្ញុំមានប្រាក់ ៤២ រៀល តើខ្ញុំទិញសៀវភៅក្បួនទន្ទួនបានប៉ុន្មានក្បាល បើសៀវភៅមួយថ្លៃ ៧ រៀល ។

ខ្ញុំគិតថាក្នុងប្រាក់ ៤២ រៀលតើមាន ៧ ប៉ុន្មានដង ដោយយកមេលេខគុណមកប្រើ ខ្ញុំឃើញថាក្នុង ៤២ មាន ៧ ប្រាំមួយដង ព្រោះប្រាំពីរ ៦ ដងត្រូវជា ៤២ ។ ធ្វើយ៉ាងនេះហៅថាធ្វើលេខចែក ។

ទីតាំងលេខចែកត្រូវសរសេរដូចខាងក្រោមនេះ

៤២ ៖ ៧ = ៦ មើលថា ៤២ចែក

| | | |
|---|---|---|
| ចំនួនតាំង ៤២ | ៧ ដើមហារ | នឹង ៧ បាន ៦ ។ នឹងធ្វើលេខ |
| ០ | ៦ ល័ព្ធ | ចែកត្រូវធ្វើដូចខាងក្រោមនេះ ។ |

លេខ ៤២ ជាចំនួនតាំង, ៧ ជាដើមហារ, ៦ ជាល័ព្ធ ។

### របៀបទី ១.- ដើមហារនិងល័ព្ធមានលេខតែមួយខ្ទង់ ។

លេខចែកដែលមានដើមហារនឹងល័ព្ធតែមួយខ្ទង់ គេប្រើតែមេលេខគុណបានហើយ ដូចខាងក្រោមនេះ

៨១ : ៩ = ៩

របៀបទី ២.- ដើមហារមានលេខ ១ ខ្ទង់ល័ព្ធច្រើនខ្ទង់ ។

ឧបមា ៥១៧៩ : ៨ = ខ្ញុំយកមួយខ្ទង់ទៅចែកមិនបានទេ ត្រូវយកពីរខ្ទង់ គឺ ៥១ ចែកនឹង ៨ បាន ៦ សល់ ៣ ខ្ញុំបញ្ចុះលេខខ្ទង់ជាប់ខាងស្តាំមកទៀតជា ៣៧ ចែកនឹង ៨ បាន ៤ សល់ ៥, ខ្ញុំបញ្ចុះ ៩ មកទៀតជា ៥៩ ចែកនឹង ៨ បាន ៧ សល់ ៣ ។

| | |
|---|---|
| ៥១៧៩ | ៨ |
| ៣៧ | ៦៤៧ |
| ៥៩ | |
| ៣ | |

របៀបទី ៣ .- ចំនួនតាំងនឹងដើមហារមានលេខច្រើនខ្ទង់ឯដើម ល័ព្ធមានតែ ១ ខ្ទង់វិញ ។

បើកាលណាយកដើមហារគុណនឹង ១០ ទៅឃើញបានចំនួនលើសចំនួនតាំងនោះគេដឹងថា ល័ព្ធ មានលេខតែមួយខ្ទង់ដូចខាងក្រោមនេះ

១៩២៨ : ៣៨៩ =

ត្រូវគិតថា ៣៨៩ ដប់ដងជា ៣៨៩០ ធំលើសជាងចំនួនតាំង ១៩២៨ ដូច្នេះគេដឹងថានៅល័ព្ធមានលេខតែមួយខ្ទង់ ។

| | | | | | |
|---|---|---|---|---|---|
| ១៩២៨ | ៣៨៩ | ១៩២៨ | ៣៨៩ | ១៩២៨ | ៣៨៩ |
| ៨៣ | ៥ | ៧៦១ | ៣ | ៣៧២ | ៤ |
| រើសហារធំពេក | | រើសហារតូចពេក | | ល្មម | |

## រង្វាស់រង្វាល់

អាទិត្យទី ១.- អំពីខ្នាតប្រវែងមានរូបជាប្រធាន ។

ប្រដាប់បង្រៀន .- សូមលោកគ្រូរកម៉ែត្រគ្រប់បែប គឺម៉ែត្រឈើ ១០ ផ្នត់, ៥ ផ្នត់, ម៉ែត្រត្រង់បួនជ្រុងដូចបន្ទាត់សំរាប់វាស់សំពត់ ម៉ែត្រសំពត់សំរាប់ជាង៍កាត់ខោអាវ, ម៉ែត្រដែក-ស្ពាន់របស់ជាង៍ដែកជាង៍ឈើ, ដេសីម៉ែត្រ, ទ្វេដេសីម៉ែត្រ, កន្ទះម៉ែត្រ, ទ្វេម៉ែត្រ កន្ទះដេកាម៉ែត្រ ដេកាម៉ែត្រនឹងទ្វេដេកាម៉ែត្រ ។

ដែលហៅថាខ្នាតប្រវែងមានរូបនោះ គឺខ្នាតណាដែលចាប់កាន់វាស់បាន ។ ទ្វេដេសីម៉ែត្រ, ម៉ែត្ររបស់ជាង៍ឈើ ។ល។ ជាខ្នាតមានរូប ឯគីឡូម៉ែត្រជាខ្នាតឥតរូប ។

ខ្នាតដែលមានរូបគឺ ដេសីម៉ែត្រ (០ម,១) ទ្វេដេសីម៉ែត្រ (០ម,២)

កន្លះម៉ែត្រ (០មុ៥) ម៉ែត្រ (១មុ) ទ្វេម៉ែត្រ (២មុ) កន្លះដេកាម៉ែត្រ (៥មុ) ដេកាម៉ែត្រ (១០មុ) ទ្វេដេកាម៉ែត្រ (២០ម ឬ ២ ដា.ម.) ។

ម៉ែត្រជាខ្នាតមានសណ្ឋានផ្សេងៗគ្នាតាមដែលត្រូវការប្រើ ។ ម៉ែត្រសំពត់ជាវត្ថុទន់, ម៉ែត្រឈើ ៤ ជ្រុងរឹងដូចបន្ទាត់ ។ ជាងថ្នេរដេរស្បែកជើង · ខោអាវប្រើម៉ែត្រទន់ធ្វើពីកណាត់សំពត់លាបថ្នាំ ។ ជាងធ្វើផ្ទះជាងឈើ ប្រើម៉ែត្រ ៥ ផ្នត់ ឬ ១០ ផ្នត់ធ្វើពីឈើ ឬ ពីលោហធាតុផ្សេងៗ ។ មានម៉ែត្រខ្លះធ្វើពីដែករស់ស្តើងត្រង់ស្លូក តែគេអាចមូរបញ្ចូលក្នុងប្រអប់តូចបាន ។ ទ្វេដេស៊ីម៉ែត្រមានស្ពានដូចបន្ទាត់ មានហាមសង្ការស្ដើង ហើយមានគូសកំរិតជាសង្ទីម៉ែត្រនិងមីលីម៉ែត្រ ។

**ការហាត់.–** ចូរបំបែកសព្វជាម៉ែត្រ ។ ៤ដ.ម. ៩ស.ម. ។ ៩ដា.ម. ៦៣ម.ម. ។ ៥ដា.ម. ៨២ដ.ម. ។ ៦០៩ ដ.ម. ៤ ម.ម. ។

## ចូររំលាយសព្វជាដេកាម៉ែត្រ

៣៣ ម.ម. ។ ៣ ម. ៩ ៤ ម. ៥ ស.ម. ។ ៧២ ហ.ម. ៦ ម. ។

## ចូររំលាយសព្វជាគីឡូម៉ែត្រ

៥៣៤ ដា.ម. ៦ ដ.ម. ។ ៦៥១៧ ដា.ម. ។ ២០ ដា.ម. ៥ម.

**បំណោទ.–** យន្តហោះមួយបើកបានចម្ងាយ ៣៨០ គ.ម. មួយ

ម៉ោង ៗ តើអាកាសយាននេះបើកបានចម្ងាយប៉ុន្មានគីឡូម៉ែត្រក្នុងមួយនាទី? ប៉ុន្មានម៉ែត្រក្នុងមួយវិនាទី?

## អាទិត្យទី ២.— អំពីខ្នាតប្រវែងមានរូបជាប្រមាន (ត) ៗ

### ខ្នាតវែងជាងម៉ែត្រ

របស់សំរាប់បង្រៀន.— ខ្សែដេកាម៉ែត្រ (១០ ម.) គ្រប់យ៉ាង នឹងខ្សែដេកាម៉ែត្រគ្រប់បែបបើរកបាន ៗ ខ្សែដេកាម៉ែត្រធ្វើពីលួសដែកធំ ៥០ កំណាត់ តគ្នានឹងក្រវិល ឬ ធ្វើពីដែកសំប៉ែតមូរបាន ៗ គេមានប្រើកន្លះដេកាម៉ែត្រ ឯដេកាម៉ែត្រធ្វើពីសំពត់ក៏ប្រើការដូចជាដេកាម៉ែត្រដែកដែរ ៗ

ការពិនិត្យមើលខ្នាតដេកាម៉ែត្រ.— ឲ្យសិស្សយកខ្សែដេកាម៉ែត្រដែកលាសន្ធឹងក្នុងទីធ្លា ហើយយកម៉ែត្ររាស់ប្រវែង ឃើញថាក្នុង ១ ដា.ម. មាន ១០ ម. គត់ ឯលេខសំរាប់កត់ចំនួនដេកាម៉ែត្រ ត្រូវសរសេរនៅខ្ទង់ទី ២ គឺខ្ទង់ដប់ ៗ

ការហាត់វាស់.— ឲ្យសិស្សស្មានទទឹង ឬបណ្ដោយទីធ្លា ហើយវាស់ជាក្រោយ ៗ ល ៗ

បំណោទ ._ សួនមួយទទឹង៤៣ម៉ែត្រ បណ្ដោយ៦៨ម. គេធ្វើរបងព័ទ្ធជុំវិញ មួយម៉ែត្រថ្លៃ៧រៀល ចូររកថ្លៃរបងនោះ;

## អាទិត្យទី៣ ._ អំពីរង្វាស់បម្លាយ

### ហិកតូម៉ែត្រនិងគីឡូម៉ែត្រ

ហិកតូម៉ែត្រ(ហ.ម.) និងគីឡូម៉ែត្រ(គ.ម.) សំរាប់វាស់តែបម្លាយណាដែលឆ្ងាយៗ ដូចជាបម្លាយពីភូមិមួយទៅភូមិមួយ, ក្រុង ១ ទៅក្រុង ១, បម្លាយផ្លូវថ្នល់, ប្រវែងស្ទឹង, ព្រែក, ទន្លេ, ។ល ។

ការហាត់វាស់.- ឲ្យសិស្សយកខ្សែដេកាម៉ែត្រវាស់ទីធ្លាសាលាឬបណ្ដោយតាមផ្លូវថ្នល់១០ខ្សែ ហើយដាក់ឲ្យសិស្សឈរបម្លាយពីគ្នា ១០ម៉ែត្រៗ នោះយើងឃើញបានបម្លាយវែងជាងដេកាម៉ែត្រ១០ដង គឺ១ហិកតូម៉ែត្រ (១ហ.ម.) ដូច្នេះក្នុង១ហ.ម.មាន១០ដា.ម. ឬ១០០ម៉ែត្រ ។ ហិកតូម៉ែត្រសរសេរនៅខ្ទង់ទី៣គឺខ្ទង់រយ ដប់ហិកតូម៉ែត្របានទៅគីឡូម៉ែត្រ (១គ.ម.) ។ ក្នុង១គ.ម.មាន១០ហិកតូម៉ែត្រឬ១០០ដា.ម.ឬ១០០០ម. ត្រូវសរសេរគីឡូម៉ែត្រនៅខ្ទង់ទី៤គឺខ្ទង់ពាន់ ។

| ពាន់ | រយ | ដប់ | រាយ |
| --- | --- | --- | --- |
| គ.ម. | ហ.ម. | ដា.ម. | ម. |

នៅតាមផ្លូវថ្នល់ គេកត់ចំនួនគីឡូម៉ែត្រ នៅលើគោលថ្មបួនជ្រុង នៅតាមផ្លូវរទេះភ្លើង គេសរសេរចំនួនគីឡូម៉ែត្រនៅលើបង្គោលឈើសម្រាប់ប្រាប់ចម្ងាយ ។

បំណោទ ៗ– ផ្លូវ ៣ ផ្លូវទី ១ ចម្ងាយ ២ គ.ម. ផ្លូវទី ២ ចម្ងាយ ១ គ.ម. ៥៨ ដាម. ផ្លូវទី ៣ ប្រវែងប្រហែលនឹងផ្លូវទី ១ ទី ២ រួមគ្នា ។ តើផ្លូវទាំង ៣ ចម្ងាយប៉ុន្មាន ។

## ធរណីមាត្រសាស្ត្រ

### អាទិត្យទី១.– អំពីត្រីកោណ

គ្រូគូរត្រីកោណនៅក្ដារខៀនបញ្ជាឲ្យសិស្សពិនិត្យមើលជ្រុងនឹងមុម រួចឲ្យរកន័យ ។ ត្រីកោណគឺជារូប ៣ ជ្រុងមានមុម ៣ ។

អំពីបាតត្រីកោណ.– ត្រីកោណមាន ៣ ជ្រុង គេយកជ្រុងណាមួយធ្វើជាបាតក៏បាន តាមធម្មតាគេយកជ្រុងណាដែលវែងជាងគេធ្វើជាបាត ជ្រុងកគជាបាតត្រីកោណកខគ ឬហៅជើងក្រោមក៏បានដូចគ្នា ។



## អំពីកំពស់ត្រីកោណ

បន្ទាត់ ខឧ សំយុងពីចំណុច ខ ចុះមកលើបន្ទាត់ កគ គឺជាកម្ពស់ត្រីកោណ កខគ បន្ទាត់នេះមកពីកំពូល ខ ត្រង់ចំមកដល់បាត កគ ចំពីមុខកំពូល ។

**អំពីមើលនិងសរសេរត្រីកោណ.–** ទីងមើលឬទីងសរសេរ ត្រីកោណ ត្រូវមើលឬសរសេរដូចជាមុមដែរគឺអក្សរកំពូលដាក់កណ្ដាល ផ្ទៃខាងលើនេះត្រូវមើលថា ត្រីកោណ កខគ

**ការហាត់ .–** ចូរគូសត្រីកោណមួយបាតប្រវែង ៨ ស. ម. កំពស់ ៥ ស.ម. ។

**អាទិត្យទី ២.–** អំពីត្រីកោណទាំងឡាយ ។

គ្រូយកបន្ទាត់ ៣ ប្រវែងគ្នាមកធ្វើជាកងត្រីកោណ ១ មានជ្រុងស្មើគ្នាទាំង ៣ នេះឈ្មោះត្រីកោណស្មើជ្រុង ។




កខ = កគ

កគ = ខគ

ខគ = កខ

ត្រីកោណស្មើជ្រុង

យកបន្ទាត់២ប្រវែងគ្នានឹងជើងប៉ាកាខ ធ្វើជាត្រីកោណមួយមានជ្រុង២ស្មើគ្នា យកក្រដាសបួនជ្រុងស្មើបត់ពីមុមមួយទៅមុមមួយក៏បានជាត្រីកោណមួយ មានជ្រុង ២ស្មើគ្នាដែរ ហៅថាត្រីកោណស្មើជ្រុងពីរ ។ កគខ ជាត្រីកោណស្មើជ្រុង ២ ។




ត្រីកោណស្មើជ្រុង ២ ត្រីកោណស្វាបក្តោង ត្រីកោណមិនស្មើជ្រុង

ឲ្យយកក្រដាសបួនជ្រុងទ្រវែងមួយសន្ទឹកបត់ពីមុមម្ខាងទៅម្ខាងកាត់បំពាក់កណ្តាល ហើយហែកយកមួយចំហៀងចេញ ដែលសល់នៅបានជាត្រីកោណ១ មានមុមកែង១ ហៅថាត្រីកោណស្វាបក្តាង បពន ជាត្រីកោណស្វាបក្តាង ។

ឯត្រីកោណមិនស្មើជ្រុង គឺត្រីកោណដែលមានជ្រុងទាំង៣មិនស្មើគ្នា ហើយមុមទាំង៣ក៏ពុំត្រូវគ្នាទៀត បយរ ជាត្រីកោណមិនស្មើជ្រុង ។

ការហាត់ .– ឲ្យសិស្សគូសត្រីកោណដែលបានរៀនខាងលើនេះ ។

**អាទិត្យទី ៣.–** អំពីចតុរង្ស (ផ្ទៃមានជ្រុង ៤) ៖

ដែលហៅថាចតុរង្ស គឺជាផ្ទៃដែលមានជ្រុង ៤ ឧទាហរណ៍ ឥដ្ឋ-ក្រាល, ស៊ុំទ្វារបង្អួច, ជញ្ជាំងផ្ទះ (ល) រាងជាចតុរង្ស ។

**អំពីផ្ទៃចតុរង្ស ៤ ជ្រុងស្មើ .–** ផ្ទៃរាង ៤ ជ្រុងស្មើគឺជាផ្ទៃមានជ្រុង៤ប្រវែងស្មើគ្នាទាំងអស់ មុមទាំង៤កំហំប៉ុនគ្នា ហើយជាមុមកែងផងៗ




កខឃគ ជាផ្ទៃ៤រាងជ្រុងស្មើព្រោះជ្រុង កខ ប្រវែងនឹងជ្រុង ខឃ នឹង គឃ ហើយនឹង គក ។

ឯរង្វាស់សម្រាប់ក្នុងការរកក្រឡាផ្ទៃផ្សេងៗ គេប្រើម៉ែត្រក្រឡា (១ម២) មើលថាម៉ែត្រក្រឡា ។

**អំពីរកផ្ទៃ ៤ ជ្រុងស្មើ .–** ទំនងរកផ្ទៃ ៤ ជ្រុងស្មើត្រូវយកប្រវែងជ្រុង (ជ្រ) គុណនឹងជ្រុង (ជ្រ)

ម២ = ជ្រ × ជ្រ

**រកជុំវិញឬរកបរិវេណ .–** ទំនងរកពាក់កណ្ដាលបរិវេណត្រូវយក

ជ្រុងគុណនឹង ២ ៗ ពាក់កណ្ដាលបរិវេណ = ជ × ២ នឹងរកបរិវេណ ត្រូវយកជ្រុងគុណនឹង ៤

$$ប = ជ \times ៤$$

ការហាត់.— ឲ្យគូសផ្ទៃ ៤ ជ្រុងស្មើ ១ ប្រវែង ៦ ស.ម. មួយជ្រុង ៗ

បំណោទ.— ស្រែ ៣ មានទំហំផ្ទៃរួមគ្នា ៩ ហ.ម ២ ស្រែទី ១ ទំហំធំលើសស្រែទី ២ ៤៨ ដាម.$^{២}$ ៧ ម$^{២}$ ហើយតូចជាងស្រែទីបី ៤៩០៧ ម$^{២}$ តើស្រែនីមួយ ៗ មានទំហំប៉ុន្មានម៉ែត្រក្រឡា ៗ

អាទិត្យទី ៤.— អំពីផ្ទៃ ៤ ជ្រុងទ្រវែង ៗ

ឲ្យសិស្សសង្កេតមើលក្ដារខៀនបញ្ឈរ ហើយឲ្យប្រដូចជ្រុង ១ នឹងជ្រុង ១ មុមមួយនឹងមុម ១ ឃើញជាជ្រុងស្របគ្នាពីរ ៗ ៗ យកកែងវាស់ ឃើញថាជាមុមកែង ដូច្នេះផ្ទៃ ៤ ជ្រុងទ្រវែងគឺជាផ្ទៃមានមុមកែង ៤ មានជ្រុងជាបន្ទាត់ស្របគ្នាពីរ ៗ ហើយប្រវែងគ្នាពីរ ៗ ៗ មានប្រវែងពីរយ៉ាងផ្សេងពីគ្នា ជ្រុងដែលវែង ហៅថាបណ្ដោយ (ប) ជ្រុងខ្លីហៅថាទទឹង (ទ)



$$ពាក់កណ្ដាលបរិវេណ = ប \times ទ$$

$$បរិវេណ = ប \times ទ \times ២$$

$$ម^{២} = ប \times ទ$$

**ចំណោទ** ៖– ក្នុងគេហដ្ឋានមួយមានបង្អួច ៩ មានកញ្ចក់ ២០ បន្ទះក្នុងបង្អួចមួយ ៗ កញ្ចក់មួយទំហំ ១២ដ.ម.ៗ ឯកញ្ចក់ព្រមទាំងថ្លៃដាក់ស្រេចថ្លៃ ២៥ រៀលមួយម៉ែត្រក្រឡា ។ តើបង្អួចកញ្ចក់ផ្ទះនោះថ្លៃប៉ុន្មាន ?

---

# ពាណិជ្ជការ

## មេរៀន ១

### ចំនួនពី ១០០ ដល់ ១០០០

*ថ្លៃដើម – ថ្លៃលក់ – ប្រាក់ចំណេញ*

**អាទិត្យទី ១.–** បង្រៀនចំនួនពី ១០០ ដល់ ៥០០

ដូចបាននិយាយពីខែមុនស្រាប់ បើនឹងបង្រៀនចំនួននីមួយ ៗ ត្រូវបញ្ជាក់ចំនួននោះ គឺត្រូវប្រើបង្កើះ ៗ

ដើម្បីនឹងបញ្ជាក់ពីខ្ទង់ទៀត សូមគ្រូរកប្រអប់ ៣ ហើយសរសេរដាក់នៅខាងមុខប្រអប់នោះថា ខ្ទង់រយ ខ្ទង់ដប់ ខ្ទង់រាយ ឧបមាដូចជា ២៣៦ ត្រូវយកចង្កឹះ ២ ដាក់ក្នុងប្រអប់ខ្ទង់រាយ មើលថាពីររយ យកចង្កឹះបីដាក់ក្នុងប្រអប់ខ្ទង់ដប់ គឺដប់បីដងត្រូវជាសាមសិប ហើយនឹងចង្កឹះរាយ ៦ ដាក់ក្នុងប្រអប់ខ្ទង់រាយ ហើយប្រាប់សិស្សថា ទាំងអស់នេះចំនួនពីររយសាមសិបប្រាំមួយ (២៣៦) ។

សូមឲ្យសិស្សរើសចង្កឹះដាក់ក្នុងប្រអប់តាមចំនួនដែលគ្រូបង្គាប់ ។ រួចគ្រូសរសេរចំនួនដែលសិស្សរកឃើញនៅលើក្ដារខៀន ។

**ហាត់មើលចំនួន.–** ឲ្យសិស្សមើលចំនួនដែលគ្រូបានសរសេរនៅក្ដារខៀន ដូចជា: ១០៣, ១១២, ២៣៥. ២៤៤. ៣០៧. ៣៦២, ៤២១. ៥០០. ៤៨៨. ៣៣៣ ។ល។

**ហាត់រាប់ចំនួន.–** ឲ្យរាប់ថែមពីរៗ បីៗ បួនៗ ប្រាំៗ ពី ១០០ ដល់ ៥០០ រួចរាប់សាចុះមកវិញ ។

**ហាត់សរសេរចំនួននៅក្ដារឆ្នួន.–** ឲ្យសិស្សសរសេរលេខតាមគ្រូថា: ១៥២ - ៣០១ - ២៧៦ - ៤៣១ - ២៨៥ - ៥០០ - ៤៩៩ ៣៦៣ ។ល។

ហាត់គិតមាត់ទទេ. ឪឡឹក ២៦៨ លក់អស់ឪឡឹក ២៥ នៅសល់ឪឡឹក.... ?

ឈ្មួញម្នាក់ផ្ទុកស្រូវក្នុងទូកមួយ ១៨.៧ ថាំង មួយទៀត ១១៤ ថាំង តើស្រូវក្នុងទូកទាំងអស់មានប៉ុន្មានថាំង ?

## អាទិត្យទី ២.- ចំនួនពី ៥១ ដល់ ១០០

(សូមបង្រៀនដូចអាទិត្យទី ១)

លេខបូកមានត្រាទុក. ម្ដាយខ្ញុំគាត់ទិញខ្សែក ១ ដុំ ថ្លៃ២៣៨៛, ខ្សែដៃ ១ ដុំថ្លៃ ១៥៩៛ ។ គាត់ប្រាប់ខ្ញុំថាឲ្យគិតរកចំនួនប្រាក់ដែលគាត់ចាយទាំងអស់ - ?

ដើម្បីនឹងរកប្រាក់ដែលអ្នកម្ដាយខ្ញុំចាយត្រូវបូកប្រាក់ថ្លៃខ្សែក ២៣៨៛, នឹង ១៥៩៛ ថ្លៃខ្សែដៃ ។

ឯធ្វើលេខបូកត្រាទុក ក៏ដូចជាលេខបូកឥតត្រាទុកដែរ គឺសរសេរចំនួនមួយក្រោមចំនួនមួយ ហើយគូសបន្ទាត់មួយនៅខាងក្រោម

```
  ២៣៨៛
+ ១៥៩៛
------
  ៣៩៧៛
```

រួចថា: ៨ នឹង ៩ ត្រូវជា ១៧ ខ្ញុំសរសេរ: លេខ ៧ នៅក្រោមខ្ទង់រាយ ខ្ញុំត្រាទុក ១ ។ ដែលត្រាទុកនឹង ៣ ត្រូវជា៤ ៗ នឹង ៥ ត្រូវជា ៩ គ្មានត្រា-

ទុកទេ ខ្ញុំសរសេរលេខ ៩ នៅក្រោមខ្ទង់ដប់ ។ ពីរនឹងមួយត្រូវជាបីខ្ញុំសរសេរលេខ ៣ នៅក្រោមខ្ទង់រយ ទាំងអស់ខ្ញុំឃើញ ៣៩៧៛ ។ ដូច្នេះអ្នកម្ដាយខ្ញុំចាយអស់ប្រាក់ចំនួន ៣៩៧៛, ។

ការហាត់.— ចូរធ្វើលេខខាងក្រោមនេះ

១៨៦ + ២៣៩ = ....... ។ ៦៩ + ២៨៥ = .......

៣១៧ + ១៨៥ = ....... ។ ១០៩ + ៣៧៤ = ......

បំណោទ.— អ្នកជំនួញម្នាក់បានលក់តុមួយថ្ងៃ ៣២៦៛ ទូតបមួយថ្ងៃ ១៩៨៛ ។ តើអ្នកជំនួញនោះបានប្រាក់ប៉ុន្មាន ?

លេខសងមានត្រាទុក .— ឧបមា: សេះមួយនឹងគោមួយទិញមកថ្លៃទាំងអស់ ៩២៣៛, ឯគោដម្លៃ ៣៧៩៛, តើសេះថ្លៃប៉ុន្មាន ? នឹងរកថ្លៃសេះ ត្រូវយកថ្លៃគោ ៣៧៩៛, ដកចេញពីថ្លៃសត្វទាំងពីរ ។ ដូច្នេះត្រូវធ្វើលេខសង គឺខ្ញុំសរសេរចំនួនតូចក្រោមចំនួនធំ ខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់រួចគេគូសបន្ទាត់មួយពីក្រោមចំនួនតូចនោះ ។

$$\begin{array}{r} ៩២៣៛ \\ -\ ៣៧៩៛ \\ \hline ៥៤៤៛ \end{array}$$

គេយកលេខពីក្រោមទៅសងលេខខាងលើតាមខ្ទង់តាំងពីខាងស្ដាំទៅ រួចគេសរសេរលេខសេស នៅខាងក្រោមខ្ទង់តាមជួរ ។

**ការបា្រត់** ៈ— ចូរធ្វើលេខសងខាងក្រោមនេះ

៧៤៩៛ - ៣២៧៛ = .......... ។ ៩០៦៛ - ២១៩៛ = ....

៥៣២៛ - ១៧៩៛ = ............ ។ ៩២១៛ - ៥៣៦៛ = ...

**បំណោទ** ៈ— អ្នកស្រែម្នាក់ធ្វើស្រែបានស្រូវ ៧៤១ ថាំង លក់អស់ម្ដង ២០៤ ថាំង ម្ដងទៀត ៣៨៦ ថាំង ។ តើអ្នកស្រែនោះនៅសល់ស្រូវប៉ុន្មានថាំងទៀត ? ។

**អាទិត្យទី ៣**.— អំពីថ្លៃដើម - ថ្លៃលក់ - ប្រាក់បំណេញ - ថ្លៃដើមមាន ២ យ៉ាង មួយយ៉ាងគឺថ្លៃដើម ប្រាក់ដែលទិញមកឥតមានសោហ៊ុយ ឬប្រាក់បន្ថែមបន្ទាប់បន្សំទៀត ឧបមាដូចជាប៉ាន់តែមួយថ្លៃ ៦៥៛ មួយយ៉ាងទៀតហៅថាថ្លៃដើម គិតរួមទាំងអស់ គឺជាថ្លៃដើមប្រាកដ ហើយថែមថ្លៃឈ្នួលដឹកនាំឬថ្លៃពន្ធ ឬដម្លៃរបស់ដែលខូចខាតទៅហើយ ត្រូវថែមដម្លៃមកលើរបស់ដែលនៅសល់ ៈហើយទឹងសោហ៊ុយដែលដាច់ខាតទាំងអស់ផង ។ ឧបមាដូចជាឈ្មួញម្នាក់ទិញនាឡិកាបង់ដៃពីស្រុកស្វិសមកលក់នៅស្រុកខ្មែរថ្លៃនាឡិកានោះមួយ ៦៥០៛, នាំចូលមកស្រុកខ្មែរត្រូវបង់ពន្ធមួយ ២១០៛, ទៀត ថ្លៃសោហ៊ុយដឹកនាំ ៨៩៛, ដូច្នេះ

ដល់មកស្រុកខ្មែរនាលិកាបង់ដៃមួយនេះ ថ្លៃដើម ៦៥០៛, + ២១០៛, + ៨៩៛, = ៩៤៩៛, បើបង្រួញមកគឺថា ថ្លៃដើម=ថ្លៃទិញ + សោហ៊ុយគ្រប់មុខ ។

ថ្លៃលក់.— ឧបមាបើគេលក់នាឡិកាបង់ដៃនោះទៅវិញ ថ្លៃ ១០០០៛, ក្នុង ១០០០៛, នេះ ឈ្មួញបានចំណេញបន្តិចបន្តួចពុំខាន គឺគេគិតយកចំណេញស្រេចទើបគេលក់ ។

បើចង់រកថ្លៃលក់ គេគិតដូច្នេះ :




ថ្លៃលក់ = ថ្លៃដើម + ប្រាក់ចំណេញ

ឬ ៩៤៩៛, + ៥១៛, = ១០០០៛,

ឯ ៥១៛, ប្រាក់ចំណេញបានមកពីធ្វើលេខ; ១០០០៛, − ៩៤៩៛, = ៥១៛,

ហាត់គិតមាត់ទទេ.— ថ្លៃដើមមានប៉ុន្មានយ៉ាង? ដូចម្ដេចហៅថាថ្លៃលក់? ប្រាក់ចំណេញ?

បំណោទ.— ១) ជាងឈើម្នាក់ ទិញទូបេងមួយថ្លៃ ៧៨១៛, លក់ទូនោះទៅវិញ ថ្លៃ ៩២៩៛, ។ តើជាងនោះបានចំណេញប៉ុន្មាន? ។

២) ឈ្មួញម្នាក់លក់ស្ករ ១០ ពាង ថ្លៃ ៥៣០រ, ហើយគាត់បាន ចំណេញ ៩០រ, ។ តើស្ករ ១០ ពាងនោះទិញមកថ្លៃប៉ុន្មាន? ។

៣) ស្រ្តីម្នាក់ទិញត្រីស្រស់ ១ ទូកតូចថ្លៃ ៣៧២រ, ។ ដល់លក់ ត្រីនោះអស់ទៅបានចំណេញ ១២៥រ, ។ តើថ្លៃលក់ត្រីទាំងអស់ប៉ុន្មាន?។

## រង្វាស់រង្វាល់

ឥឡូវនេះ ខ្មែរ ច្រើន ប្រើ ម៉ែត្រ វាស់ បណ្ដោយទទឹង កំពស់វត្ថុ ទាំងឡាយ ប៉ុន្តែ នៅស្រុកស្រែ គេនៅ ប្រើ ខ្នាត ពីដើមនៅឡើយ គឺហត្ថខ្នាតហ្វូង ។

ហត្ថ ខ្នាត ហ្វូង ប្រវែង ប្រហែល ០ម ៥០ ដូច្នេះ ក្នុង ១ ម៉ែត្រ មាន ២ ហត្ថ

រង្វាស់ ធំ ជាង ហត្ថខ្នាត ហ្វូង គឺ;

១)– ព្យាម មាន ៤ ហត្ថ ប្រហែល ពីរម៉ែត្រ ។

២)– សិន មាន ២០ ព្យាម " ៤០ ម៉ែត្រ ។

៣)–យោជន៍ មាន ៤០០ សិន" ១៦ គីឡូម៉ែត្រ ។

រង្វាស់ តួបដាន៍ហត្ថខ្នាត ហ្វុង គឺ:

១)- បំអាម គឺ ពាក់កណ្ដាលហត្ថ ឬ ០ម៉ែ២៥ ។

២)- ធ្នាប់ គឺ ១២ ភាគតួបដាន៍បំអាមត្រូវជា០ម៉ែ០២ ។

ដែលបានបែងចែក ខាងមុខចែកគប្បីទទេរហួយបារ៉ះទៅលក្ខិត្តមួយ ៤ មុំគ្រឹស្ត ០៥ ពាយ័បរាការគុលពិ –(៣

ដែលមុំគ្រទចែកលហុកិច្ចប្រកិះទៅវិវេមួយ ៤ គម្ពុ ៥ ម៉ឹហ ៣ គប្បី ២ ចូរប្រកិតាឃ្លីង ១ ថ្ងៃ (១ – ខយបទុ

ម្មុំគ្រ ០១ ទល់កខ្មោតគប្បីទទេក មុំគ្រ ១ ទល់កខ្មោត្រូវហ៊ំមួយមើម៉ឹហទទេរ

ទទេភាពួយបល្ហើរវិទ្ធមើ្ដមួយ ។ មុំគ្រស្ថិតទទេកលហុកិ ក្រុមើទទេកទទេគម្ពុ ១ ទ្រូ –ខាងមុខគម្មុយ

| | | |
|---|---|---|
| មុំគ្រស្ថិត ៤១ = | លហុកិ | ទល់ ០០៣ = ខ្ទុបភោរ |

០០ ឆ ៍០៣ = „ ០៣៥១ = „ ០៤១ „ ០២ = „ ០៣ = ទល់

០០ ឆ ៍៣ = „ ៤៥ = „ ២ „ ៣ = គប្បី

០៥ ឆ ៍០ = „ ៣៣ = „ ៣ = ច្រូហ៊ំមួយមើម៉ឹហ

៥៣ ឆ ៍០ = „ ៣១ = គម្ពុ

៣០ ឆ ៍០ = ក្រុមើ

## មេរៀនប្រជុំវត្ថុលយ

# មធ្យមដ្ឋានទី១

## នព្វន្ត

អាទិត្យទី១. លេខបូកមានត្រាទុក

(សូមមើលរបៀបនៅថ្នាក់អាទិកដ្ឋានខាងលើនេះ)

អាទិត្យទី២. លេខសងមានត្រាទុក

(សូមមើលរបៀបនៅអាទិកដ្ឋាន)

បំណោទ — ១) ពាងមួយមានចំណុះ ៣២៦ លីត្រ គេចាក់ទឹកដាក់ពាងនោះ ១៧៨ លីត្រ តើគេត្រូវចាក់ដាក់ក្នុងពាងនោះប៉ុន្មានលីត្រទៀតទើបពេញ ? ។

២). ឪពុកខ្ញុំទិញរទេះកង់មួយថ្លៃ ៩៣៦ រៀល ថ្លៃឈ្នួលដឹកនាំ ៣៧ រៀល គាត់លក់ទៅវិញបានប្រាក់ ១០០០ រៀល តើគាត់បានចំណេញប៉ុន្មាន ? ។

## រង្វាស់រង្វាល់

អាទិត្យទី១. ដេកាម៉ែត្រ - ហិកតូម៉ែត្រ - គីឡូម៉ែត្រ

ប្រដាប់សម្រាប់បង្រៀន — សូមឲ្យរកម៉ែត្រ ១, ដេកាម៉ែត្រដែក ១ ។

របៀបបង្រៀន.— សូមឲ្យយកម៉ែត្រវាស់បញ្ជាក់ប្រវែងដេកាម៉ែត្រ ផ្ទាំងហៅថា (ខ្សែនដាប៉ង់ទ័រ) ឲ្យសិស្សសង្កេតមើលក្រឡស្គាល់ប្រយោជន៍ផង ។ សូមឲ្យបញ្ជាក់សិស្សឲ្យប្រាកដមែនទែនអំពីដេកាម៉ែត្រ ពាក្យដេកា មានន័យថា ១០ ។

ការហាត់វាស់.— ឲ្យសិស្សស្ទាបប្រវែង ទីធ្លាសាលាឬផ្លូវថ្នល់ រួចយកដេកាម៉ែត្រមកវាស់បញ្ជាក់

ការហាត់គិត.— មានប៉ុន្មានម៉ែត្រ ក្នុង ៥ ដេកាម៉ែត្រ, ក្នុង ១០ ដេកាម៉ែត្រ ២០ ដេកាម៉ែត្រ? ។ មានប៉ុន្មានដេកាម៉ែត្រក្នុង ៣០ ម៉ែត្រ, ៩០ ម៉ែត្រ, ៧០ ម៉ែត្រ?

ការហាត់សរសេរ.— ជាងដេរម្នាក់ទិញសំពត់មួយ ៧២ម មួយទៀត ២៩ម អ្នកនោះទិញសំពត់ប៉ុន្មានដេកាម៉ែត្រ ។

ខ្ញុំដើរទៅសាលារៀន មានចម្ងាយ ៥៦៨ម ខ្ញុំត្រឡប់មកតាមផ្លូវ ១ទៀត មានចម្ងាយ ៣៩២ម ខ្ញុំដើរបានចម្ងាយប៉ុន្មានដេកាម៉ែត្រ? ។

អាទិត្យទី ១ – អំពីហិកតូម៉ែត្រ – គីឡូម៉ែត្រ

អាទិត្យទី ២ – អំពីដេកាលីត្រ – ហិកតូលីត្រ

អាទិត្យទី ៣ – អំពីដេកាក្រាម – ហិកតូក្រាម – គីឡូក្រាម

# មជ្ឈិមដ្ឋានទី ១

## ធរណីមាណសាស្ត្រ

អាទិត្យទី ១ និងទី ២ – អំពីលក្ខណៈនៃបន្ទាត់ត្រង់

បន្ទាត់កែង. ឲ្យសិស្សពិនិត្យមើលឈើកែងរបស់ជាងឈើ ប្រើសំរាប់ផ្ទៀងឲ្យត្រឹមត្រង់ជ្រុង ។ កែងនេះមានសណ្ឋានជាបន្ទាត់កែង ។

បន្ទាត់កែង គឺបន្ទាត់ត្រង់មួយសំយុងត្រង់លើបន្ទាត់ត្រង់មួយទៀតជួនខ្វែងជាជើងក្អែកក៏មាន ។

(សូមគ្រូមើលសេចក្ដីណែនាំ ក្នុងសៀវភៅក្បួនទនទ្ដសំរាប់អាទិកដ្ឋានទំព័រទី ១១៨ វគ្គទី ២ ។

អាទិត្យទី ៣ និងទី ៤ – ការគូរបួនជ្រុងស្មើ និងបួនជ្រុងទ្រវែង

របៀបបង្រៀន.– គូរគំនូរបួនជ្រុងស្មើនៅលើក្ដារខៀនដោយប្រើប្រដាប់ឈានត្រឹមត្រូវឲ្យសិស្សមើលគូរតាម នាំសិស្សពិនិត្យមើល តើជ្រុងទាំងអស់ពងជាបន្ទាត់អ្វី (បន្ទាត់កែង) ប្រវែងស្មើគ្នាឬទេ ? ។

ឲ្យសិស្សគូរបួនជ្រុងស្មើដោយមានជ្រុង តាមកំរិតដាក់ឲ្យ ។ មើលគំនូរក្នុងសៀវភៅក្បួនទនទ្ដសំរាប់អាទិកដ្ឋាន ទំព័រទី ១២២ វគ្គទី៣ ឯរបៀបបង្រៀនបួនជ្រុងទ្រវែងក៏ដូចគ្នាដែរ ។

# កុមារដ្ឋាន

## គណិត

**មេរៀនទី ១.** – ចំនួនពី ១០ ដល់ ១៩ ការរៀបរាប់ - មើល - សរសេរចំនួន

**របស់សំរាប់បង្រៀន.** – ចង្កឹះកាយ - ចង្កឹះដប់ចងជាបាច់ លុយសេន ប្រាក់កាក់ ១០ សេន ៗ

**របៀបបង្រៀន.** – ១ - សួរសាកបញ្ជាក់ចំនួនដែលបានរៀនពីថ្ងៃមុន ( ពី ១ ដល់ ៩ ៗ

២– រៀនចំនួន ១០ - គ្រូបើកចង្កឹះ ៩ បង្ហាញសិស្ស ឲ្យរាប់ថាចំនួននោះ រួចបន្ថែមចង្កឹះ ១ ទៅលើចំនួននោះត្រូវជាប៉ុន្មាន ( ត្រូវជា ១០ ) ៗ

៣– គ្រូសរសេរចំនួន ១០ នៅលើក្ដារខៀនហើយសួរសាកពន្យល់សិស្សអំពីរបៀបសរសេរចំនួន ១០ នោះ

៤– គ្រូឲ្យសិស្សអានចំនួនដែលសរសេរនៅលើក្ដារខៀន

៥– ឲ្យសិស្សសរសេរចំនួន ១០ នៅលើក្ដារឆ្នួន

កាលណាសិស្សស្គាល់-បេះគាន-បេះសរសេរចំនួន ១០ ហើយលោកគ្រូបង្រៀនចំនួន ១១ តទៅទៀតតាមរបៀបខាងលើនេះប៉ុន្តែត្រូវពន្យល់សិស្សឲ្យយល់ច្បាស់អំពីខ្ទង់នៃលេខដូចជា១៣ គេត្រូវសរសេរលេខ ១ នឹង លេខ ៣ នៅខាងស្តាំ លេខ ១ នៅខ្ទង់ ១០ ដូចជាបង្កើះ ១០ មួយបាច់ ឬប្រាក់កាក់ ១០ សេនមួយនឹងបង្កើះរាយ ៣ ឬលុយសេន ៣ នៅខ្ទង់រាយ

កាលណាសិស្សបេះរាប់ - បេះគាន - បេះសរសេរចំនួនពី ១០ ដល់ ១៩ ហើយត្រូវសាបញ្ជាក់ឡើងវិញ អំពីការរៀនរាប់ - រៀនគាន រៀនសរសេរចំនួនពី ១០ ដល់ ១៩ តាមរបៀបដែលតែងជូនជាគំរូពីមុននោះស្រាប់ហើយ ។

មេរៀនទី ២.- ចំនួនដល់ ១៩ – រៀនធ្វើលេខបូក

របៀបបង្រៀន.- ១– ការហាត់គិតមាត់ទទេឲ្យសិស្សរាប់បង្កើះបន្ថែម ពីរៗ បីៗ បួនៗ ពី ១ដល់១៩

២ ការពន្យល់របៀបធ្វើលេខបូក.- សិស្សម្នាក់កាន់បង្កើះ ១២ ម្នាក់ទៀតកាន់បង្កើះ ៤ តើសិស្សទាំងពីរនាក់មានបង្កើះប៉ុន្មាន ។ គ្រូធ្វើលេខបូកនេះនៅលើក្តារខៀន ហើយពន្យល់របៀបធ្វើ៖

$$\begin{array}{r} ១២ \\ + \ ៤ \\ \hline ១៦ \end{array}$$

៣. ការហាត់បញ្ជាក់នៅលើក្តារខៀន៖ ១៤ស + ៣ស ។ ១៣ស + ៤ស ។ ១១ស + ២ស ។ល។

៤– ការហាត់បញ្ចូលនៅលើក្ដារខៀន ៖ ១៣ស + ២ស ។ ១៥ស + ៤ស= ។ ១៣ស + ៦ស= ។ ១៤ស + ៤ស= ។

## មេរៀនទី៣.– ចំនួន ១៩– រៀនធ្វើលេខសង

សុំធ្វើតាមរបៀបបង្រៀនធ្វើលេខបូកខាងលើនេះ ហើយសុំតែងការហាត់ឲ្យបានសព្វគ្រប់ផង ។

## មេរៀនទី ៤ .– សាបង្រៀនឡើងវិញ

បញ្ចូលអំពីចំនួនដល់ ១៩– អំពីលេខបូក– អំពីលេខសង ដែលបានរៀនកន្លែងនេះ ហើយសុំតែងការហាត់ឲ្យសព្វគ្រប់ផង ។

# រង្វាស់រង្វាល់

## មេរៀនទី ១._ អំពីរង្វាស់ម៉ែត្រ (ក)

យើងបានបង្រៀនសិស្សឲ្យស្គាល់ប្រវែង ១ ម៉ែត្រ រាប់ទាំងស្មានប្រវែង ១ ម៉ែត្រផង ។ ក្នុងខែនេះយើងត្រូវបង្រៀនឲ្យស្គាល់រង្វាស់ម៉ែត្រគ្រប់បែប ហើយនឹងការប្រើប្រាស់រង្វាស់ម៉ែត្រគ្រប់បែបនោះផង ។

**របស់សំរាប់បង្រៀន** _ ម៉ែត្របត់ ម៉ែត្របន្ទាត់-ម៉ែត្រសំពត់- របស់សំរាប់វាស់នឹងម៉ែត្របន្ទាត់ដូចជាខ្សែ ឬសំពត់ ។

របៀបបង្រៀន.– ១ - សួរសាកបញ្ជាក់អំពីរង្វាស់ម៉ែត្រ ។

២– បង្រៀនឲ្យស្គាល់រង្វាស់ម៉ែត្រគ្រប់បែប គឺគ្រូលើកម៉ែត្រទាំង ៣ បែបបង្ហាញសិស្ស សួរសាកនាំសិស្សពិនិត្យមើលម៉ែត្រ ១ បែប ៗ អំពីរូបរាងនិងប្រវែង ឲ្យឃើញថា រូបរាងខុសគ្នា ប៉ុន្តែប្រវែងស្មើគ្នាទាំងអស់ ។

៣– អំពីរបៀបប្រើប្រាស់ម៉ែត្រ ១ បែប ៗ គឺនាំសិស្សរៀនធ្វើជាងឈើដែលជាអ្នកប្រើម៉ែត្របត់ ធ្វើអ្នកលក់សំពត់ជាអ្នកប្រើម៉ែត្របន្ទាត់ត្រង់ ជាងកាត់ដេរខោអាវជាអ្នកប្រើម៉ែត្រសំពត់ ។

៤– ការហាត់គិតមាត់ទទេ.– នាំសិស្សនិយាយគិតដោយមាត់ទទេ គឺបូក សងតាមវិធីដែលបានរៀនទន្ទួន ។ ការហាត់គិតនេះសុំលោកគ្រូតែងតាមដំរិះរបស់សិស្សបុះ ។

មេរៀនក្រោយ ៗ ទៀតសុំលោកគ្រូចាត់ចែងឲ្យបានស្រួលផង ព្រោះក្នុងខែនេះ ត្រូវបង្រៀនតែអំពីម៉ែត្រគ្រប់បែបនិងការប្រើប្រាស់ម៉ែត្រទាំងនោះ ហេតុនេះសុំលៃពេលបង្រៀនឲ្យសមតាមពេលនឹងមេរៀន ។

# បរិច្ឆណាដ្ឋាន

សប្ដ ១

មេរៀនទី ១ .– ចំនួនពី ១០០ ដល់ ១១៩ . ការរៀនរាប់-រៀនអាន-រៀនសរសេរចំនួន ៗ

របស់សំរាប់បង្រៀន .– បំពង់ ៣ សំរាប់ខ្ទង់រយ ១ ខ្ទង់ដប់ ១ និងខ្ទង់រាយ ១ ហើយនិងបន្ទះឈាបពណ៌បីបែប ១ បែបសំរាប់ខ្ទង់រយ ១ បែបទៀតសំរាប់ខ្ទង់ ១០ ហើយនិង ១ បែបទៀតសំរាប់ខ្ទង់រាយ




មួយរាយ ដប់ បី

របៀបបង្រៀន . ១. គ្រូដាក់បន្ទះ នៅក្នុងបំពង់ដូចរបៀបខាងលើនេះ

២  សួរសាកសិស្សអំពីចំនួនដែលបានអំពីរបៀបដាក់ចង្កឹះក្នុងបំពង់ខាងលើនេះ ហើយពន្យល់អំពីខ្ទង់

៣– គ្រូសរសេរចំនួននោះនៅលើក្ដារខៀន ហើយពន្យល់របៀបសរសេរចំនួននោះ ។

៤– កាលណាសិស្សយល់ហើយ គ្រូថាចំនួន ឲ្យសិស្សរៀបចង្កឹះដាក់បំពង់ - ឲ្យសិស្សសរសេរចំនួននោះនៅលើក្ដារខៀន - ឲ្យសិស្សមើលចំនួនដែលសរសេរនៅលើក្ដារខៀន - ឲ្យសិស្សសរសេរចំនួននោះនៅលើក្ដារឆ្នួន ។

ធ្វើតាមរបៀបនេះរាល់តែសិស្សចេះមើលចេះសរសេរចំនួនពី ១០០ ដល់ ១១៩ ។

៥– សាបញ្ជាក់ឡើងវិញអំពីវិជ្ជា ដែលទើបនឹងបង្រៀននេះ គឺ បញ្ជាក់អំពីការរៀនពប់ គឺរបៀបរៀបចង្កឹះដាក់បំពង់ - របៀបមើលចំនួន- របៀបសរសេរចំនួន ។

៦– ការហាត់គិតមាត់ទទេ ។

៧– ការហាត់សរសេរនៅក្នុងសៀវភៅ ។

សូមលោកគ្រូតែងការហាត់ខាងលើនេះផងចុះ

មេរៀនទី ២.– ចំនួនពី ១០០ ដល់ ១១៩ . រៀនធ្វើលេខបូកចំនួនជុំ ឥតត្រាទុក នឹងមានត្រាទុក ។

របៀបបង្រៀន.–

១– ការពន្យល់របៀបធ្វើលេខនៅលើក្ដារខៀន

| | | |
|---|---|---|
| ១០៣ស | ១០២ស | ៨៥ស |
| +១៤ស | + ៩ស | +២៧ស |

មេរៀនទី ៨.– សាបង្រៀនវិជ្ជាដែលបានបង្រៀនក្នុងថ្ងៃនេះ ឡើងវិញ ៗ

## រង្វាស់រង្វាល់

មេរៀនទី ១.– អំពីរង្វាល់លីត្រ -

ធ្វើដូចរបៀបដែលបង្រៀនអំពីរង្វាស់ម៉ែត្រ គឺ៖

១ នាំសិស្សពិនិត្យមើលរង្វាល់ លីត្រ

២. នាំសិស្សហាត់ប្រើប្រាស់រង្វាល់នោះ

៣– នាំសិស្សហាត់គិត

មេរៀនទី ២.- អំពីលីត្រគ្រប់បែប - និងការប្រើប្រាស់នៃលីត្រមួយបែបៗ

មេរៀនទី ៣.- អំពីកូនទម្ងន់ក្រាម

មេរៀនទី ៤.- អំពីទម្ងន់គីឡូក្រាម

មេរៀនទី ៥.- អំពីមុម

សុំតែងការហាត់ឲ្យបានសព្វគ្រប់តាមរបៀបដែលតែងជូនជាគំរូ នៅក្នុងទស្សនាវដ្ដីលេខ ១ សព្វគ្រប់ស្រាប់ហើយ ។

---

## មជ្ឈមណ្ឌលទី ២

## វិទ្យាសាស្ត្រ

មេរៀនក្នុងខែ .- អំពីវិញ្ញាណប្រាំ ។ ១ ចក្ខុវិញ្ញាណ សោតវិញ្ញាណ និងឃានវិញ្ញាណ ។ ២. ជិវ្ហាវិញ្ញាណនិងកាយវិញ្ញាណ ។ ៣. គ្រឿងប្រដាប់សំរាប់រំលាយអាហារ ។ ៤. ការរំលាយអាហារ ។

មេរៀនគំរូ .- អំពីចក្ខុវិញ្ញាណ

**ប្រដាប់សំរាប់បង្រៀន** សូមគ្រូរកភ្នែកគោឬជ្រូក ទីងផ្ទាំងគំនូរភ្នែកមនុស្ស មានភាពផ្សេងៗ មកនាំសិស្សពិនិត្យមើល ។ល។

**ការពិនិត្យមើលនិងពន្យាករណ៍** ១ បើគ្មានប្រដាប់សុំនាំសិស្សឲ្យពិនិត្យមើលភ្នែកគ្នាឯង ដែលនៅជិតៗគ្នា តាមចំណែកដែលបានអធិប្បាយជូនខាងក្រោយនេះ ។

២ – នាំសិស្សពិនិត្យមើលភ្នែកម្នាក់ ដែលគ្រូបង្គាប់ឲ្យមើលតាមបង្អួច រួចឲ្យសំឡឹងមើលទៅគៀនមួយ ដែលងងឹតនោះទៀត នោះគេនឹងឃើញដូចម្តេច ។ល។

**អំពីគ្រឿងវិញ្ញាណ** យើងមានវិញ្ញាណប្រាំគឺ ចក្ខុវិញ្ញាណ (ភ្នែក) សោតវិញ្ញាណ (ត្រចៀក) ឃានវិញ្ញាណ (ច្រមុះ) ជីវ្ហាវិញ្ញាណ (អណ្តាត) កាយវិញ្ញាណ (ដៃឬថាស្បែកក៏បាន) ។

**យើងពណ៌នាអំពីភ្នែក** ម្តេចហៅថាភ្នែក ភ្នែកគឺជាចក្ខុវិញ្ញាណ មានរាងមូលដូចជាគ្រាប់ឃ្លី តែកំប៉ោងខាងមុខបន្តិច) (សូមបង្ហាញរូប-ភាពនៃភ្នែកមនុស្សយើង) ។ យើងមានភ្នែកប៉ុន្មាន? (យើងមានភ្នែកពីរ) ភ្នែកនៅក្នុងអ្វី ; (ភ្នែកនៅក្នុងរន្ធឆ្អឹងមុខ – ហៅថារន្ធភ្នែក) ។ នៅខាង-លើរន្ធភ្នែកមានអ្វី នៅខាងលើរន្ធភ្នែកមានរោមដុះជាជួរ ហៅថា

ចិញ្ចើម មានរោមគោងបន្តិច) ចិញ្ចើមនេះមានប្រយោជន៍ឬទេ? (ចិញ្ចើមមានប្រយោជន៍នឹងការពារញើស កុំឲ្យហូរចូលភ្នែកយើងបាន) ។ យើងមានត្របកភ្នែកប៉ុន្មាន? (យើងមានត្របកភ្នែកពីរ គឺត្របកភ្នែកលើមួយក្រោមមួយ សំរាប់បើកបិទភ្នែក នៅវេលាដែលត្រូវការបើកបិទម្តងៗ) នៅលើត្របកភ្នែកទាំងពីរនេះមានអ្វីដែរឬ? (មានរោមខ្លីៗដុះតាមហាមត្របកភ្នែកនោះ ហៅថារោមភ្នែក) ។ រោមភ្នែកសរាប់ធ្វើអ្វី? (សំរាប់ការពារកុំឲ្យធូលី ឬសំរាមអ្វីចូលក្នុងភ្នែកយើងបាន) ។ នៅក្នុងផ្លែភ្នែកយើងតើអ្នកឃើញដូចម្តេច? (នៅក្នុងផ្លែភ្នែកយើង សើមជាដរាបនឹងទឹកភ្នែក) ។ ភ្នែកជាដុំមូលហើយស ហៅថាប្រស្រីស ។ តើនៅកណ្តាលប្រស្រីសនេះអ្នកឃើញដូចម្តេច? (ឃើញខ្មៅធុះបាន) ។ តើគេហៅថាអ្វី? (គេហៅថាកែវភ្នែកនេះ មានដូចជារនាំង ហើយមានរន្ធតូចមួយសំរាប់ឲ្យពន្លឺចូលរនាំងនឹងរន្ធតូចនេះ ហៅថា ប្រស្រីខ្មៅ ។ (សូមនាំសិស្សពិនិត្យមើលឲ្យឃើញជាក់ផង) ។ នៅខាងក្នុងប្រស្រីខ្មៅនេះទៅទៀត មានស្រទាប់មួយទៀត ហៅថា ស្រទាប់ទទួលពន្លឺមានសុទ្ធតែសរសៃ ហៅថា សរសៃចក្ខុវិញ្ញាណ ។ ពន្លឺទាំងប៉ុន្មានដែលចូលទៅក្នុងភ្នែកយើងនោះ ស្រទាប់ទទួលពន្លឺទទួលយកទាំងអស់ ហើយសរសៃ ចក្ខុវិញ្ញាណ នាំចូលទៅក្នុងខួរក្បាលទៀត ប្រយោជន៍ឲ្យយើងមើលឃើញរបស់ផ្សេង ៗ នៅជុំវិញខ្លួនយើង ។ (សូមធ្វើព្យាករណ៍ឲ្យសិស្សមើលឃើញផង បើធ្វើបាន) ។

**មេរៀនសង្ខេប** .– ភ្នែកជាគ្រឿងវិញ្ញាណមួយយ៉ាងសំខាន់ណាស់សំរាប់ឲ្យយើងមើលឃើញ វត្ថុផ្សេងៗនៅជុំវិញខ្លួនយើង បើយើងខូចភ្នែកទាំងពីរ ពុំអាចមើលអ្វីឃើញឡើយ យើងបានសេចក្ដីវេទនាយ៉ាងខ្លាំងបំផុត ។ ភ្នែកមានចិញ្ចើម គ្របភ្នែកនឹងរោមភ្នែក សំរាប់ការពារ កុំឲ្យញើសដែលហូរនៅលើថ្ងាស ឬសំរាម ធូលីអ្វីចូលភ្នែកយើងបាន ។ យើងក្រលៀសភ្នែកយើងបានដោយងាយ ពីព្រោះរង្វង់ភ្នែកយើងសើមជានិច្ច កែវភ្នែកមានរាងមូល ដូចជាគ្រាប់កូនឃ្លី នៅក្នុងរង្វង់ភ្នែកនោះ ។ នៅខាងមុខមានស្រទាប់ ប្រស្រីភ្លុះបាន នៅខាងក្រោយមានដូចជារនាំង ហើយមានរន្ធតូចមួយ – សំរាប់ឲ្យចូលពន្លឺហៅថាប្រស្រីខ្មៅ នៅខាងក្នុងភ្នែក មានស្រទាប់មួយទៀត សំរាប់នាំពន្លឺទាំងឡាយចូលទៅក្នុងខួរក្បាល ដើម្បីឲ្យយើងមើលឃើញរបស់ផ្សេងៗដែលនៅជុំវិញខ្លួនយើង ហៅថាសរសៃចក្ខុវិញ្ញាណ ។

**ពាក្យសួរក្នុងមេរៀន** .– ភ្នែកសំរាប់ធ្វើអ្វី ។ បើជាយើងខូចភ្នែកទាំងពីរ នោះយើងនឹងបានសេចក្ដីយ៉ាងណាខ្លះ ។ ល ។

## អនាម័យ

**មេរៀនក្នុងខែ** .– ១ ការសំអាតស្បែក ។ ២ ការសំអាតខ្លួន ។ ៣ ការសំអាតដៃ – ត្រចៀក – សក់ ។ ៤– ការថែរក្សាធ្មេញ ។

មេរៀនជាគំរូ .– អំពីការថែរក្សាធ្មេញ .

ប្រដាប់សំរាប់បង្រៀន .– សូមគ្រូរកច្រាសដុសធ្មេញ ថ្នាំដុសធ្មេញ ផ្ទាំងគំនូរធ្មេញជាសុខសប្បាយ ធ្មេញដង្កូវស៊ីតិចដង្កូវស៊ីច្រើន ៗ ល ៗ មកឲ្យសិស្សពិនិត្យមើល ៗ

ធ្មេញជាគ្រឿងប្រដាប់មួយសំខាន់ណាស់ ប្រយោជន៍នឹងទំពាអាហារឲ្យហ្មត់ហ្មង ៗ បើសិនណាយើងទំពា ឲ្យគ្រាន់តែទក់ៗ ហើយលេបអាហារនោះទៅ តើវានឹងបណ្ដាលឲ្យយើងមានរោគយ៉ាងណាខ្លះ ៗ វាបណ្ដាលឲ្យយើងឈឺក្រពះបាយ នឹងបង្កើតរោគផ្សេងៗ មានជម្ងឺមូល (ជាដើម) ៗ ដើម្បីនឹងចៀសវាងរោគទាំងឡាយនេះ តើយើងត្រូវធ្វើដូចម្ដេច ? (យើងត្រូវថែរក្សាធ្មេញយើង ឲ្យបានស្អាតជាដរាបប្រយោជន៍កុំឲ្យដង្កូវស៊ី) ធ្មេញដង្កូវស៊ីបណ្ដាលហេតុយ៉ាងណាខ្លះ ? (វាបណ្ដាលឲ្យ ឲ្យឈឺយ៉ាងខ្លាំង សឹងតែទ្រាំអត់ពុំបាន មួយទៀតទំពាអាហារកំពុំស្រួលបានល្អិតទេ ហើយអាហារនោះបណ្ដាលឲ្យយើងឈឺក្រពះបាយនឹងពោះវៀនទៀតផង ៗ ហេតុនេះចូរយើងសំអាតធ្មេញ ឲ្យស្អាតមែនទែន កុំធ្វេសប្រហែសឡើយ គឺដុសលាងធ្មេញនៅវេលាបរិភោគបាយរួច ឬយកសំពត់យ៉ាងស្អាតជ្រលក់ទឹករួចរុំនឹងម្រាមដៃដុសជូតចេញឲ្យស្អាតៗម្យ៉ាងទៀត, បើអ្នកធ្វើបាន, ចូរអ្នកដុសលាងធ្មេញអ្នក នឹងច្រាសដុសធ្មេញ

ពេលព្រឹក - ល្ងាច នឹងសាប៊ូថ្នាំសំរាប់ដុសលាងធ្មេញ ឲ្យបានសព្វគ្រប់ គឺពីក្រោមទៅលើ ពីលើចុះក្រោម តាមបណ្ដោយជើងធ្មេញ ហើយដុសចាំងខាងក្នុង ខាងក្រៅធ្មេញ បើសិនជាដុសលាងបានពេលវេលាដែលបរិភោគអាហាររួច នោះក៏កាន់តែណាស់ទៅទៀត ។

**មេរៀនសង្ខេប.-** ធ្មេញជាគ្រឿងប្រដាប់មួយដ៏សំខាន់ណាស់ សំរាប់ទំពាអាហារឲ្យបានហ្មត់ហ្មង ដូច្នេះចូរយើងថែរក្សាធ្មេញយើងឲ្យស្អាតកុំឲ្យដង្កូវស៊ី ។ ធ្មេញដង្កូវស៊ី ទំពាអាហារមិនបានល្អិតល្អទេ នាំឲ្យពុំស្រួលដល់ការរំលាយអាហារផង ។ ប្រយោជន៍កុំឲ្យដង្កូវស៊ីធ្មេញ យើងត្រូវដុសលាងយ៉ាងហោចណាស់ នឹងសំពត់ជ្រលក់ទឹកពេលព្រឹកល្ងាច ។ បើសិនជាធ្វើបាន ត្រូវដុសលាងសំអាតធ្មេញយើងនឹងច្រាសសំរាប់ដុសធ្មេញ ពេលវេលាដែលបរិភោគបាយរួច ។ ទំលាប់ដុសលាងធ្មេញឲ្យស្អាតនេះ ជាការមួយប្រសើរណាស់ ដើម្បីឲ្យបានសុខសប្បាយខ្លួន មិនសំគាល់ជារូបប្រុសឬស្រីទេ ។

**ពាក្យសួរក្នុងមេរៀន.-** ធ្មេញជាគ្រឿងប្រដាប់ដូចម្ដេច ? ។ យើងត្រូវថែរក្សាធ្មេញយើងឲ្យស្អាតឬទេ ? ។ ពីព្រោះអ្វី ? ។ ធ្មេញដង្កូវស៊ី នោះនឹងបណ្ដាលឲ្យមានហេតុយ៉ាងណាខ្លះ ? ។ យើងត្រូវធ្វើម្ដេច កុំឲ្យដង្កូវស៊ីធ្មេញបាន ។ បើធ្មេញជាល្អ តើមានប្រយោជន៍យ៉ាងណាខ្លះ ? ។ល។

## ឧត្តមដ្ឋាន

### វិទ្យាសាស្ត្រ

មេរៀនក្នុងខែ.— កំណត់ចែកវិជ្ជាបង្រៀនក្នុងខែតុលានេះដូចគ្នានឹងថ្នាក់មធ្យមដ្ឋានទីពីរដែរ ដូច្នេះសូមបង្រៀនតាមថ្នាក់នោះផងចុះ ។ មួយវិញទៀតកាលពីឆ្នាំសិក្សា ១៩៥០-៥១ នោះខ្ញុំបានជូនមេរៀនជាគំរូខ្លះហើយ ទៅវេលានេះនឹងជូនមេរៀនជាគំរូមួយទៀតដូចមានតទៅ ។

មេរៀនជាគំរូ.— ការរំលាយអាហារ

ប្រដាប់សំរាប់បង្រៀន.— សុំយកផ្ទាំងរូបគំនូរគ្រឿងប្រដាប់សំរាប់រំលាយអាហាររបស់មនុស្ស មកបង្ហាញសិស្ស ហើយនាំសិស្សពិនិត្យមើល តាមលំអាននៃមេរៀនខាងក្រោមនេះ ។

សេចក្តីពន្យល់.— អាហារទាំងឡាយ ដែលយើងបរិភោគរលាយទៅជាត្ករ ជ្រាបចូលទៅក្នុងឈាម ប្រយោជន៍នឹងទ្រទ្រង់ជីវិតយើង ឲ្យរស់នៅ ហើយបញ្ចេញវត្ថុណាដែលសៅហ្មងទៅក្រៅ ។

**យើងបរិភោគអាហារដូចម្ដេច.–** យើងកាន់យកអាហារដាក់ទៅក្នុងមាត់ ធ្មេញនឹងថ្គាមទំពាលំអិតអាហារនោះ ទឹកមាត់ចេញមកផ្សំអាហារ ប្រយោជន៍ឲ្យអណ្ដាតក្រលៀវលេបចូលតាមបំពង់កទៅក្នុងក្រពះបាយ ។ នៅក្នុងក្រពះនេះមានអាបោធាតុមួយ បន្ទន់អាហារឲ្យទន់រលាយដូចជាបបរ ចុះទៅក្នុងពោះវៀននេះទៀត មានធាតុមួយយ៉ាងទៀត មកផ្សំរំលាយអាហារនោះជាបង្ហើយ ។ល។

**បរិយោសាន.–** ដើម្បីឲ្យបានសេចក្ដីសុខសប្បាយខ្លួននោះ យើងត្រូវបរិភោគអាហារចំណីដូចម្ដេច ។

១ – មិនត្រូវបរិភោគចំណីអាហារឲ្យច្រើនហួសកំរិតទេ ហើយទំពាឲ្យល្អិតមែនទែន ចូររើសរកតែអាហារណាដែលល្អបរិសុទ្ធផង ។ បើយើងបរិភោគអាហារច្រើនពេក ក៏នាំឲ្យយើងបានផលអាក្រក់ ដូចជាបរិភោគចំណីអាហារតិចពេកដែរ ។ ចូរយើងកុំបរិភោគឲ្យខុសពេលធម្មតា នឹងធ្វើឲ្យក្រពះបាយស្ពឹកឥតប្រយោជន៍ ។

២ - ចូរបរិភោគសាច់នឹងស៊ុតឲ្យតែល្មម កុំបរិភោគឲ្យច្រើនហួសកំណត់ ពីព្រោះសាច់នឹងស៊ុតនោះ នឹងបណ្ដាលឲ្យមានជាតិពុលទៅក្នុងពោះវៀន ហើយបង្កើតឲ្យមានជម្ងឺក្នុងថ្លើមទៀតផង ។

៣ – ចូរបរិភោគបន្លែឲ្យច្រើន នឹងជូនសេចក្ដីសុខសប្បាយខ្លួន ត្រូវបរិភោគតែបន្លែណា ដែលនាំឲ្យមានកម្លាំងដល់ខ្លួនយើង ។ ចំណីអាហារខ្លះ នាំឲ្យមានកំដៅតិច ដូចជាត្រសក់ ស្ពៃ ប៉េងប៉ោះ ។ល។

**មេរៀនសង្ខេប.–** អាហារដែលយើងបរិភោគនោះ ចូលទៅក្នុងមាត់ មានធ្មេញសំរាប់ទំពាកំទេចទៅជាដុំតូចៗ រួចទឹកមាត់ផ្សំអាហារនោះ ឲ្យរអិលចូលទៅក្នុងក្រពះបាយតាមបំពង់ក ។ នៅក្នុងក្រពះបាយនេះ មានអាបោធាតុមួយ វាយលំអិតអាហារនោះឲ្យម៉ដ្ឋទៅទៀត ទើបធ្លាក់ចុះទៅក្នុងពោះវៀន ។ នៅកន្លែងនេះមានធាតុម្យ៉ាងទៀត លំអិតអាហារនេះ ឲ្យកាន់តែម៉ដ្ឋផង់ណាស់ទៅទៀត ចំណែកអាហារដែលរលាយទៅជាទឹក ជ្រាបចូលទៅក្នុងពោះវៀនលាយនឹងឈាម ឯកាកអាហារដែលឥតប្រយោជន៍ ក៏ចេញទៅខាងក្រៅ ។

យើងត្រូវបរិភោគអាហារឲ្យតែល្មម ទំពាឲ្យល្អិតមែនទែន ហើយផ្លាស់ប្ដូរអាហារឲ្យញយៗផង ។ កុំបរិភោគសាច់និងស៊ុតច្រើនពេកពីព្រោះវាបណ្ដាលឲ្យមានជម្ងឺពោះវៀននឹងថ្លើម ។

**ពាក្យសួរក្នុងមេរៀន.–** អាហារដែលយើងបរិភោគនោះតើទៅឯណា ។ វាចូលទៅឯណាទៀត ។ អ្វីវាយលំអិតអាហារនៅក្នុងក្រពះបាយ ។ ល ។

## ខ អនាម័យ

មេរៀនក្នុងខែ.– កំណត់ចែកវិជ្ជាបង្រៀនអនាម័យ ទៅថ្នាក់ឧត្តមដ្ឋាន ក្នុងខែតុលានេះក៏ដូចគ្នានឹងថ្នាក់មធ្យមដ្ឋានឆ្នាំទីពីរដែរ ដូច្នេះ សូមលោកគ្រូយកមេរៀនអនាម័យសំរាប់ថ្នាក់មធ្យមដ្ឋាន ឆ្នាំទីពីរមក បង្រៀនសិស្សផងចុះ ។

---

## អាទិកង្គន

### វិត្ថាធ្យាយន៍

### អំពីសត្វ

សូមគ្រូនាំសិស្សពិនិត្យមើលសត្វខ្លះដែលគួរទុកធ្វើជាគំរូ ឆ្មា, គោ, មាន់, បង្កួយ, កង្កែប, ត្រី, មេអំបៅ, ខ្យង, ដង្កូវ ។

អាទិត្យទី១.– មេរៀនលេខ ១

### អំពីឆ្មា

១.- ខ្លួនឆ្មា.– សូមគ្រូឲ្យសិស្សចាប់ឆ្មាមួយមកបង្រៀននាំសិស្សពិនិត្យ រូបរាងសត្វឆ្មាៗឲ្យសិស្សសង្កេតមើលខ្លួនឆ្មាៗរាងដូចម្ដេចៗនាំសិស្សស្ទាប

រោម ៗ ដូចអ្វី? (វែងហើយរលើបដូចសូត្រ) ។ ឲ្យសង្កេតមើលក្បាល, មាត់ ។ ភ្នែកឆ្មាយ៉ាងដូចម្តេច? កាលណាពន្លឺច្រើនភ្នែកឆ្មាដូចម្តេច? នៅក្នុងទីងងឹតឆ្មាដើរកាត់បានឬទេ? ពុកមាត់ឆ្មាប្រយោជន៍អ្វី? (ប្រយោជន៍នឹងស្ទាបនៅទីងងឹត) ត្រចៀកឆ្មាវែងឬទេ? ឆ្មាស្រង់ក្លិនបានឆ្ងាយឬជិត? ឆ្មាលបចាប់កណ្តុរធ្វើដូចម្តេចខ្លះ?

២- ក្រចកឆ្មា — ឆ្មាមានជើងបួនក្នុងជើងនិមួយៗមានម្រាមប្រាំគឺជាសត្វចតុបាទ ។ នៅចុងម្រាមជើងមានក្រចកពងកោងខុបចុះក្រោម ស្រួចលើបបួលលូតចេញបានតាមចិត្ត ។ ឯក្រចកនេះសំរាប់ចាប់ក្រញាំសត្វជាអាហារ កាលណាវាដើរវាលាក់ក្រចកដើម្បីកុំឲ្យសឹក) ។

៣- ធ្មេញឆ្មា.- គ្រូបើកមាត់ឆ្មានាំសិស្សមើលធ្មេញថ្គាម ។ ថ្គាមវែងឬខ្លី? ថ្គាមវែងនឹងថ្គាមខ្លីថ្គាមណាខ្លាំងជាង? ចង្កូមឆ្មាកងដូចម្តេច? សម្រាប់ខាំអ្វី

៤.- អាហារឆ្មា.- ឆ្មាស៊ីអ្វី? វាចាប់សត្វអ្វីខ្លះយកមកបរិភោគ? សត្វណាខ្លះនៅក្នុងព្រៃដែលបរិភោគសាច់ដូចឆ្មា?

## មេរៀនលេខ២.- អំពីមាន់

របស់សំរាប់បង្រៀន.- គ្រូត្រូវរកមាន់រស់មួយនឹងពងមាន់ ។ នាំសិស្សពិនិត្យមើលភ្នែកវាតូចហើយមូល ត្រចៀកវាគ្មានស្លឹកទេ ។ កវាបត់បានតាមចិត្ត ។ ជើងវាមានស្រកាហើយមានក្ពាល់ជង ។ ស្លាបវាគេកាបទងទាញ

ត្រជាក់បាន ។ លើក្បាលវាមានសេរ ។ មាន់ជាសត្វពងហើយក្រាបកំរែត ២១ ថ្ងៃនឹងញាស់បានជាកូនមាន់)។

## អាទិត្យទី២.- មេរៀនលេខ១.— អំពីកង្កែប.

របស់សំរាប់បង្រៀន.- គ្រូត្រូវរកពងកង្កែបហើយនឹងកូនក្អាត់ដាក់ក្នុងកែវ រកកង្កែបរស់មួយផង ។ នាំសិស្សពិនិត្យមើលក្បាលវាពងវែង, ភ្នែកវាធំ ៗ រង្វះមាត់ធំជិតមកត្រចៀក ។ ជើងវាបួន ។ ជើងមុខមានម្រាមបួនហើយខ្លី ។ ជើងក្រោយវែងហើយមាំ មានម្រាមប្រាំជាប់នឹងស្បែកស្តើង ។ កង្កែបមិនចេះដើរទេ វាលោតគឺជាសត្វនៅលើគោកក៏បាន នៅក្នុងទឹកក៏បាន ។

មេរៀនសង្ខេប .- កង្កែបមានជើងបួន ។ ជើងពីរខាងមុខខ្លី ជើងពីរខាងក្រោយវែងហើយមាំ ។ ជើងក្រោយនេះហើយដែលវាសំរាប់លោតនឹងហែលទឹក ។ ស្បែកវារលើង, ត្រជាក់ហើយសើមជានិច្ច គឺជាសត្វនៅក្នុងទឹកក៏បានលើគោកក៏បាន ប៉ុន្តែវាត្រូវការនឹងខ្យល់អាកាសដើម្បីនឹងដកដង្ហើមដូចសត្វដទៃឯទៀតដែរ ។ វាកើតអំពីពង ក្នុងរវាងពីរបីថ្ងៃ ពងនោះញាស់បានជាកូនក្អុក គឺជាសត្វខ្លួនតូចក្បាលធំ កន្ទុយវែងគ្មានជើង ហើយដកដង្ហើមយកខ្យល់តាមស្រកីដូចជាត្រី មិនយូរប៉ុន្មានកូនក្អុកនោះធំឡើងដុះជើងជ្រុះស្រកីទៅហើយ កន្ទុយកាន់តែរួញ ៗ

ទៅលុះតែបាត់អស់ គេហៅថាកូនក្អាត់យូរទៅកូនក្អាត់នោះទៅជាមណ្ឌុកជាតិ ហើយដកដង្ហើមតាមសួតវិញ ។ ក្នុងពួកមណ្ឌុកជាតិ មានសត្វកង្កែប, គីង្គក់, ហ៊ឹង ។ ល ។

## មេរៀនលេខ ២ .– អំពីត្រី

សូមគ្រូមើលក្នុងសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់អាទិកដ្ឋានទំព័រទី២៩ ។

## អាទិត្យទី៣ .– មេរៀនលេខ ១ .– អំពីមេអំបៅ.

របស់សំរាប់បង្រៀន .– គ្រូត្រូវរកមេអំបៅមួយកុំឲ្យដាច់ដោយអ្វីទាំងអស់ នាំសិស្សពិនិត្យមើលមេអំបៅមានប៉ុន្មានចំណែក ? អ្វីខ្លះ ? មានស្លាបប៉ុន្មាន ?

មេរៀនសង្ខេប .– ខ្លួនមេអំបៅមានបីចំណែកៈ គឺក្បាល, ទ្រូង និងពោះនៅក្បាលមានមាត់ ឯមាត់នេះបែបជាបំពង់តូចមួយសំរាប់ជញ្ជក់អាហារ ។ មានភ្នែកពីរធំហើយមានកំប៉ោយហៅថា (ចូឡា) ដូចជាស្នែងកំរើកបាន ។ នៅទ្រូងមានជើងប្រាំមួយហើយធម្មតាមានស្លាប ៤ ។

## អាទិត្យទី ៤ .– មេរៀនលេខ ១– ការចិញ្ចឹមសត្វ–

សូមគ្រូមើលមេរៀនក្នុងទស្សនាវដ្តីឆ្នាំសិក្សា ១៩៥០ – ៥១, ខែ-តុលា ទំព័រទី ៨៧ ។

មេរៀនលេខ ២.– ដង្កូវនាង

របស់សំរាប់បង្រៀន .– មេអំបៅ – សំបុកនាង – សំបុកកាត់ ដឹកដឿ ស្លឹកមន (បើគ្មានរបស់អស់នេះត្រូវគូររូបជំនួស) ។

មេរៀនសង្ខេប .– ប្រៀបដូចជាមេអំបៅដង្កូវនាង មុនដំបូងជាពងតូចមួយ ពងនោះញាស់បានជាដង្កូវនាង យូរបន្តិចទៅដង្កូវនោះក៏ធ្វើសំបុកមួយចូលទៅនៅក្នុងនោះកើតជាដឹកដឿនៅស្ងៀម ហើយពុំមានស៊ីអាហារឡើយ បន្តិចទៅដឹកដឿនោះដុះស្លាបហើយកាត់សំបុកចេញមកជាមេអំបៅ ។ (សូមគ្រូដេញដោលសិស្សអំពីផលប្រយោជន៍ដង្កូវនាង)

---

## អាទិកឃ្លួន

## វិធីបង្ការរោគ

អាទិត្យទី១– មេរៀនលេខ១– ត្រូវប្រើទឹកនឹងសាប៊ូដុសសំអាតខ្លួន ខ្លួនយើង·មុខ.ដៃនឹងជើង តែងតែមានធូលីមកប៉ះពាល់ប្រឡាក់ជានិច្ច ។ ហេតុនេះត្រូវងូតទឹកដុសលាងមុខនឹងទឹកក្ដៅក៏បាន ទឹកត្រជាក់ក៏បានតែ

បើទំលាប់ប្រើទឹកក្ដៅបាននោះជាការសំខាន់ណាស់ ព្រោះទឹកក្ដៅអាចនឹងរំលាយជាតិក្អែលនឹងជាតិខ្លាញ់បានស្រួល ទឹកត្រជាក់លាងខ្លាញ់មិនជ្រះស្អាតទេ ។ បើយើងប្រើទឹកក្ដៅយើងមិនប្រើសាប៊ូបាន ។ តែបើយើងប្រើទឹកត្រជាក់តោងតែប្រើសាប៊ូផង ។ ព្រោះសាប៊ូរំលាយជាតិខ្លាញ់បានហើយសម្លាប់មេរោគផង ។ បើយើងប្រើតែទឹកទទេ ទឹកមិនអាចនឹងជំរះជាតិខ្លាញ់នឹងសម្លាប់រោគបានឡើយ ។

រាល់តែល្ងាចបើរួចការងារហើយ ត្រូវងូតទឹកដុសសាប៊ូលាងជំរះខ្លួនប្រាណទើបបានសេចក្ដីសុខសប្បាយ ។

## មេរៀនលេខ១២ ‧— ត្រូវប្រើទឹកនឹងសាប៊ូដុសសំអាតខ្លួន (ត)

ចូរយើងដុសលាងដៃនឹងសាប៊ូ វេលាមុនបរិភោគអាហារហើយនឹងវេលាត្រឡប់មកពីបង្គន់វិញ ។ ចូរយើងកុំភ្លេចថាដៃនេះហើយដែលសំរាប់ចាប់កាន់អាហារបរិភោគ ។ ក្រចកអ្នកណាមានក្អែលខ្មៅ គេសំគាល់ថាមនុស្សនោះស្មោកគ្រោក ត្រូវឆ្កឹះជូតដុសក្រចករាល់ថ្ងៃ ។ ត្រូវរកបំណែកឫស្សីតូចមួយចិតឲ្យស្រួច យកមកឆ្កឹះក្រចកបានហើយ កុំយកម្រាមដៃមកបៀមក្នុងមាត់ ។

អាចម៍ក្រចកខ្មៅក្រខ្វក់នេះ គឺជាលក្ខណការស្មោកគ្រោក មួយទៀតគឺជាការអន្តរាយផង ។

## អាទិត្យទី២ មេរៀនលេខ ១– ការថែរក្សាធ្មេញ–

សូមមើលក្នុងសៀវភៅវិធីបង្ការរោគសំរាប់បរិច្ឆណដ្ឋាន ទំព័រទី ១៥

## មេរៀនលេខ ២.– ការថែរក្សាធ្មេញ –(ត)

## អាទិត្យទី ៣.– មេរៀនលេខ ១ – ការថែរក្សាសក់

ត្រូវដុសលាងសក់នឹងទឹកលាយសាប៊ូ ៨ ថ្ងៃ ១ ដង ៗ នៅស្រុកស្រែណាដែលគេរកសាប៊ូប្រើជានិច្ចមិនបាន ត្រូវយកក្បុងដូងមកព្រោះយកទឹកឬយកផ្លែសំបួរមកកកក់ក្បាលក៏បានដែរ ៗ ត្រូវថែរក្សាក្រាសស្និតប្រាសកន្ត្រៃកាត់សក់ឲ្យស្អាតមែនទែន ៗ របស់សំអាងខ្លួនទាំងអស់នេះត្រូវទុកប្រើប្រាស់សំរាប់តែខ្លួនអ្នក ៗ ចូរអ្នកប្រយ័ត្នអ្នកកាត់សក់ ត្រូវប្រាប់គេឲ្យលាងដៃឲ្យយកក្រាសកន្ត្រៃទៅពេលអណ្តាតភ្លើងដុតស្រា មុននឹងយកមកកាត់សក់អ្នក ៗ ធ្វើដូច្នេះអ្នកនឹងចៀសវាងជម្ងឺធ្ងន់ តែងតែកើតមានដល់ស្បែកក្បាល ៗ

# មជ្ឈិមដ្ឋានទី ១

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១– មេរៀនលេខ ១.- កាយ វិញ្ញាណ ៖- ស្បែក·

កាយវិញ្ញាណដឹងដោយប៉ះពាល់ដល់ស្បែកគ្រប់អន្លើខ្លួនយើង ប៉ុន្តែស្បែកដៃច្រើនដឹងជាងគេ ។ ស្បែកមានពីរស្រទាប់ ស្រទាប់មួយស្តើងនៅខាងលើហៅថាស្បែកក្រៅ ស្រទាប់មួយទៀតក្រាស់នៅខាងក្រោមហៅថាស្បែកក្នុង នៅក្នុងស្រទាប់ក្រោមនេះមានសរសៃសំរាប់បង្ហូរញើសចេញមក កាលណាប៉ះពាល់នឹងរបស់ ដៃអាចឲ្យយើងដឹងថារបស់នោះត្រជាក់ ឬ ក្តៅមានរាងយ៉ាងដូច្នេះ ដូច្នោះ រឹងឬទន់ ។ ម្រាមដៃសំរាប់ឲ្យយើងកាន់យករបស់ ពីព្រោះវាមានសន្លាក់បត់បាន ។

មេរៀនលេខ ២ - ចក្ខុ ញ្ញាណ ៖ ភ្នែក·

ភ្នែកយើងប្រៀបដូចជាដុំមួយមូលនៅក្នុងរន្ធធំហៅថារន្ធភ្នែក ។ ឯភ្នែកឬដុំមូលនោះកើតអំពីជាតិមួយ ស ហៅថាប្រស្រីសនៅជ្រុងខាងមុខភ្នែកស្រទាប់ប្រស្រីសនេះធ្លុះបាន ហើយគេហៅថាកែវភ្នែក នៅខាង

ក្រោយកែវនោះ មានដូចជាជាំងបញ្ឈរ មានរន្ធតូចមួយសំរាប់ឲ្យពន្លឺចូលបាន រនាំងនឹងរន្ធតូចនេះគេហៅថាប្រស្រីខ្មៅ នៅខាងក្នុងទៀតមានស្រទាប់មួយទៀតហៅថាស្រទាប់ទទួលពន្លឺ ស្រទាប់នេះសុទ្ធតែសរសៃបែកចេញពីសរសៃមួយហៅថាសរសៃចក្ខុវិញ្ញាណ ។ ពន្លឺទាំងប៉ុន្មានដែលចូលទៅក្នុងភ្នែកយើងនោះ ស្រទាប់ទទួលពន្លឺ ទទួលយកទៅទាំងអស់ ហើយសរសៃចក្ខុវិញ្ញាណនោះនាំចូលទៅក្នុងខួរក្បាល ដូច្នេះបានជាយើងឃើញរបស់អ្វី ៗ ទាំងពួងនៅជុំវិញយើង ។

ភ្នែកយើងមានរោមចិញ្ចើមគ្របការពារពីលើចុះមកក្រោមបន្តិចមានគ្របកហៅថាគ្របកភ្នែកនិងរោមភ្នែក ។

ទឹកភ្នែកមានដក់នៅក្នុងអណ្តូងមួយកំពស់ស្មើនឹងសៀតផ្កា គៀនសង់ខាងភ្នែក ។

## អាទិត្យទី២. មេរៀនលេខ ១ – សោតវិញ្ញាណ ៖ ត្រចៀក ។

ត្រចៀកជាប្រដាប់សំរាប់ឲ្យឮសព្ទសូរទាំងពួង សូរនោះគឺជារបស់ញ័រមកប៉ះនឹងត្រចៀកដោយខ្យល់អាកាសឬដោយរបស់ដ៏មានរូបនាំមក ។ ត្រចៀកនមួយ ៗ បែកជាបីសង្កាត់គឺត្រចៀកក្រៅត្រចៀកកណ្តាលត្រចៀកក្នុង ។

ត្រចៀកក្រៅមានស្លឹកត្រចៀកហើយនឹងប្រហោងត្រចៀក ត្រចៀកកណ្ដាល បែបដូចជាប្រអប់មានក្រដាសនៅខាងក្នុងខណ្ឌពីត្រចៀកក្នុង ឯក្រដាសនេះសន្ទឹងដូចជាស្បែកដែលគេពាសស្គរ ។

ត្រចៀកក្នុងនៅជាប់ទឹងធ្អឹងមួយរឹងហើយមានរន្ធច្រើន ឯរន្ធមួយវៀនដូចជាខ្យងក្នុងរន្ធនេះមានសរសៃសោតវិញ្ញាណ បែកមកពីខួរក្បាល សូរសំឡេងដែលមកប៉ះនឹងស្លឹកត្រចៀកចូលទៅដល់សរសៃសោតវិញ្ញាណតាមក្រដាសត្រចៀកសរសៃនេះនាំដំណឹងទៅដល់ខួរក្បាល ។

## មេរៀនលេខ១២ - ជិវ្ហាវិញ្ញាណ- អណ្ដាត. និងឃានវិញ្ញាណ: ច្រមុះ

ជិវ្ហាវិញ្ញាណក៏ដូចជាកាយវិញ្ញាណដែរ គឺដឹងដោយសារអណ្ដាតនិងស្បែកមាត់ ។ អណ្ដាតគឺជាសាច់ដុំមួយនៅកណ្ដាលមាត់ ហើយនៅលើអណ្ដាតនោះមានកន្ទួលតូចៗ ច្រើនដ៏មានសរសៃវិញ្ញាណតូចៗមកដុះភ្ជាប់សរសៃនេះនាំដំណឹងរសជាតិទៅប្រាប់ខួរក្បាល ។

សរសៃជិវ្ហាវិញ្ញាណនេះដឹងជាតិអាហារផ្សេងៗ លុះតែអាហារនោះរលាយ ។ យើងដឹងក្លិននឹងច្រមុះ ។ ច្រមុះមានប្រហោងពីរហៅថាប្រហោងច្រមុះហើយនឹងឆ្អឹងច្រមុះមានរន្ធពីរទៀតគឺរន្ធច្រមុះ ។ នៅក្នុងច្រមុះមានសរសៃឃានវិញ្ញាណមកដុះភ្ជាប់ជាច្រើន ហើយមានរោមដុះផង ឯរោមនេះសំរាប់បង្ការកុំឲ្យផង់ធូលីចូលនៅក្នុងច្រមុះបាន ។

## អាទិត្យទី៣- មេរៀនលេខ១- ការរំលាយអាហារ

ឯការរំលាយអាហារអាចធ្វើឲ្យអាហារយើងបរិភោគរលាយទៅជាវត្ថុរាវ ហើយចូលទៅលាយនឹងឈាមបាន ។

អាហាររលាយក្នុងគ្រឿងប្រដាប់សំរាប់រំលាយគឺមាត់ (នៅក្នុងមាត់នោះមានធ្មេញ អណ្តាតផ្សែមទឹកមាត់) បំពង់ក, ក្រពះ ពោះវៀន ថ្លើម នឹងប្រម៉ាត់ ។ អាហារដែលទឹកមាត់ផ្សំរួចហើយនោះចូលតាមបំពង់ក ទៅក្នុងក្រពះបាយ ក្នុងនោះមានអាហោធាតុមួយទៀតមកបន្ទន់អាហារឲ្យទន់មែនទែន អាហារនោះរលាយទៅដូចជាបបរចេះទៅក្នុងពោះវៀនមានអាហោធាតុមួយផ្សេងទៀតមកផ្សំរំលាយបង្ហើយ អាហារនោះ ឯចំណែកអាហារណាដែលចូលតាមពោះវៀនបានក៏ចូលទៅលាយនឹងឈាម ឯចំណែកអាហារមួយទៀតដែលពុំត្រូវការក្នុងខ្លួនមនុស្សយើងនោះក៏ចេញមកចោលខាងក្រៅ ។

## មេរៀនលេខ២- ការដកដង្ហើម

ការដកដង្ហើមអាចឲ្យយើងស្រូបយកខ្យល់អាកាសចូលទៅក្នុងខ្លួនប្រយោជន៍នឹងឲ្យទៅច្រោះឈាម មនុស្សក្តី សត្វក្តីរុក្ខជាតិក្តី បើគ្មានដកដង្ហើមនឹងស្លាប់ ខ្យល់អាកាសដែលស្រូបនោះចូលទៅក្នុងខ្លួន តាមច្រមុះ

ហើយទឹកមាត់ រួចទៅខាងក្រោមបំពង់អាហារ ចូលទៅតាមបំពង់ខ្យល់ធ្លាក់ទៅដល់សួត នៅដើមបំពង់ខ្យល់មានប្រដាប់មួយហៅថាកន្ទើតៗនេះជាប្រដាប់សំរាប់ឲ្យឮសំឡេងនៅខាងចុងបំពង់ខ្យល់មានបំពង់ពីរទៀតហៅថាទងសួត ទងសួតចូលទៅដល់ក្នុងសួត បែកប្រពាក់គ្នាជាច្រើនឥតគណនា សួតនៅក្នុងទ្រូង សួតមួយនៅខាងឆ្វេង មួយទៀតនៅខាងស្តាំ ហើយមានដូចជាថង់មួយរុំព័ទ្ធជុំវិញ ហៅថាស្រោមសួត ។

ការដកដង្ហើមចូលជាការដែលយើងស្រូបខ្យល់ចូលមកក្នុងខ្លួនយើង ឯខ្យល់នោះចូលដល់ក្នុងសួតអាចឲ្យសួតហើយទ្រូងប៉ោងឡើង ។ ឯការដកដង្ហើមចេញ ជាការយើងបញ្ចេញខ្យល់ពីក្នុងខ្លួនយើង នាំឲ្យសួតហើយទ្រូងផតចុះទៅ ។

ដូច្នេះយើងរាល់គ្នាត្រូវទំលាប់រៀនស្រូបខ្យល់តាមច្រមុះ កុំស្រូបតាមមាត់ ។

## អាទិត្យទី ៤.- មេរៀនលេខ ១-ការឈាមរត់ក្នុងខ្លួន

ឈាមរត់ចូលសព្វកន្លែងក្នុងខ្លួនយើង ហើយហូរពុំមានឈប់សោះឡើយ បើកាលណាឈាមលែងរត់យើងស្លាប់ ។

គ្រឿងប្រដាប់សំខាន់នាំឈាមរត់គឺ បេះដូង ឯបេះដូងនោះគឺជាសាច់ដុំមានប្រហោងក្នុងហើយមានសួតនៅអមសងខាង ។

ឈាមរត់តាមសរសៃឈាម ៗ ចែកជាសរសៃនាំឈាមក្រហមមកពីបេះដូងហើយចែកជាសរសៃតូច ៗ រួចមះ២សរសៃនាំឈាមខ្មៅចូលទៅបេះដូងវិញ  កាលណាបេះដូងរួមរួញទៅឈាមបាញ់ចេញទៅក្នុងខ្លួនយើងតាមសរសៃឈាមក្រហម ហៅថា មេសរសៃឈាមក្រហម សរសៃនេះចែកជាសរសៃតូច ៗ ច្រើនណាស់ទៅទៀត  កាលណាឈាមលែងចោលអាហារហើយ ៗ វាផាប់កំទេចកំទីដែលនាំឲ្យវាខ្មៅនោះ វាត្រឡប់មកបេះដូងវិញតាមសរសៃឈាមខ្មៅ ហើយឈាមនោះហូរទៅក្នុងសួតរួចវាចេញមកវិញមានពណ៌ក្រហមដោយសារមានធាតុខ្យល់ម្យ៉ាងបាពាំងហៅថា ( ឱកស៊ីហ្សែន = Oxygéne ) ៗ វាយព្រោះយកកំទេចកំទីនោះចេញហើយហូរត្រឡប់ចូលក្នុងបេះដូងវិញរួចហូរចែកទៅពាសពេញក្នុងខ្លួនយើង ។

កាលណាឈាមហូរបន្តិច ៗ ម្ដង គ្រឿងប្រដាប់ក្នុងខ្លួនយើងទទួលអាហារកាន់តែតិច ៗ ទៅ ហើយក៏ផ្សាយទៅ  ហេតុដូច្នេះយើងពុំត្រូវស្លៀកពាក់ខោអាវចង្អៀតឡើយ  ពីព្រោះតែវាបង្អាក់ផ្លូវឈាមរត់ ។

## មេរៀនលេខ ២ - រៀនសាឡើងវិញ

# វិធីបង្ការរោគ

## ការថែរក្សាខ្លួន

អាទិត្យទី ១ .– ការថែរក្សាមាត់និងធ្មេញ.

សូមមើលក្នុងសៀវភៅវិធីបង្ការរោគទំព័រទី១៥ - ១៦

អាទិត្យទី ២ .– ការថែរក្សាភ្នែក

សូមមើលសៀវភៅដដែលទំព័រទី ១៨ - ១៩ - ២០ - ២១

អាទិត្យទី ៣ .– ការថែរក្សាត្រចៀក

សូមមើលសៀវភៅដដែលទំព័រទី ២២ - ២៣

អាទិត្យទី ៤ .– វិធីបង្ការរោគចំពោះការដកដង្ហើម

មេរៀន.– ដើម្បីឲ្យបានសុខសប្បាយខ្លួនត្រូវចេះដកដង្ហើមហើយដកតែអាកាសល្អ ៗ

ក) ប្អូនរៀនដកដង្ហើម.- ប្អូនដកដង្ហើមតាមច្រមុះ កុំដកដង្ហើមតាម.មាត់ ៖ តាមរន្ធច្រមុះ អាកាសឡើងក្តៅហើយ ជ្រះធូលីដែលជាប់មេរោគចេញអស់ ៗ យូរ ៗ គេរាន់ដកដង្ហើមឲ្យបានវែងមួន ដើម្បីកំចាត់ខ្យល់ឲ្យអស់ចេញពីសួត ៗ

១) ចូរដកដង្ហើមតែអាកាសសុទ្ធ.– អាកាសសុទ្ធមានតាមមាត់សមុទ្រ និងទីភ្នំ ។ នៅស្រុកស្រែក៏មានអាកាសសុទ្ធដែរ ឲ្យតែខុសពីទីបឹងកន្លែងតាក់ដី ។ ចូរកុំអាស្រ័យដំណេកគ្នាច្រើនពេកក្នុងបន្ទប់បិទជិត៖ អ្នកនឹងឈឺក្បាលឬវិលមុខ ។ ចូរបើកទ្វារបង្អួចឲ្យស្រឡះ ។ ចូរទន្ទាប់ដើរយកខ្យល់អាកាស តែចូរកុំឲ្យប៉ះខ្យល់ត្រជាក់ឲ្យសោះកាលណាអ្នកកំពុងបែកញើស ។

សូមគ្រូតែងពាក្យសួរនឹងមេរៀនសង្ខេបផងចុះ ។

---

# កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី ១.– អំពីថ្ងៃ

សូមគ្រូរកប្រក្រតិទិនបារាំងខ្មែរមកឲ្យសិស្សមើលថ្ងៃខែផង ។

គណាត់ពេលវេលាក្នុងមួយថ្ងៃ ពីអធ្រាត្រទៅទល់នឹងថ្ងៃត្រង់ហៅជាព្រឹក ពីថ្ងៃត្រង់ទៅទល់នឹងអធ្រាត្រហៅជាល្ងាច ពេលទាំងពីរនេះមួយៗមាន ១២ ម៉ោង មួយម៉ោងមាន ៦០ មីនុត មួយមីនុតមាន ៦០ នាទី ។

ក្នុងមួយអាទិត្យមានប្រាំពីរថ្ងៃ ឲ្យសិស្សរាប់ថ្ងៃទាំង ៧ នោះ ៗ

ក្នុងមួយខែមាន ២៩ ថ្ងៃ ឬ ៣០ ថ្ងៃ ១២ ខែត្រូវជាមួយឆ្នាំ ៗ

## អាទិត្យទី ២.— អំពីខែ

សូមគ្រូរកមហាសង្ក្រាន្តខ្មែរមកបង្ហាញឲ្យបេះមើលផង ខែខ្មែរចែកជាពីរចំណែក គឺខ្នើតមាន ១៥ ថ្ងៃ រនោចមាន ១៤ ថ្ងៃ ឬ ១៥ ថ្ងៃ ៗ ថ្ងៃ ១៥ កើត គេហៅថាថ្ងៃពេញបូណ៌មី ពីព្រោះយប់ថ្ងៃនោះព្រះចន្ទ្រភ្លឺពេញរង្វង់ ថ្ងៃ ១៤ ឬ ថ្ងៃ ១៥ រោចគឺថ្ងៃខែដាច់ ៗ

ដូច្នេះក្នុងមួយខែខ្មែរមាន ២៩ ថ្ងៃឬ ៣០ ថ្ងៃជាកំណត់ដរាប ក្នុង ១ ឆ្នាំមាន ១២ ខែ ៗ

(ឲ្យសិស្សមើលលើមហាសង្ក្រាន្តខ្មែរ ៗ)

គឺខែមិគសិរ – បុស្ស មាឃ – ផល្គុន – ចេត្រ – ពិសាខ – ជេស្ឋ អាសាឍ – ស្រាពណ៍ – ភទ្របទ – អស្សុជ និងកត្តិក ឲ្យរៀនសំគាល់លេខខែផង ជាការមានប្រយោជន៍ក្នុងសំបុត្រស្នាមដូចជាគេសរសេរថា ថ្ងៃ ២ ៣ ១០ គឺជាថ្ងៃចន្ទ្រ ៣ កើតខែភទ្របទ ៗ

មេរៀនសង្ខេបសូមឲ្យគ្រូតែងឲ្យសិស្សរៀនផងចុះ ៗ

## អាទិត្យទី ៣.- អំពីរៀនមើលប្រក្រតីទិន

យកប្រក្រតីទិនមកបង្ហាញឲ្យសិស្សមើលថ្ងៃ ខែ ៗ

## អាទិត្យទី ៤.- អំពីរដូវនៅស្រុកខ្មែរ

នៅនគរខ្មែរយើងតាមធម្មតា មានរដូវពីរគឺ រដូវប្រាំងនឹងរដូវវស្សា រដូវប្រាំងចាប់តាំងពីពាក់កណ្ដាលខែកត្ដិក ទៅទល់នឹងពាក់កណ្ដាលខែជេស្ឋ រដូវវស្សា ពីពាក់កណ្ដាលខែជេស្ឋទៅទល់ដើមខែកត្ដិក ។

រដូវប្រាំងគ្មានភ្លៀងធ្លាក់ទេ. គឺជារដូវមានប្រយោជន៍. ខាងអ្នកធ្វើបំការ. រដូវវស្សាត្រូវខាងអ្នកដែលធ្វើស្រែ. ។

សូមគ្រូពន្យល់នឹងតែងសេចក្ដីសង្ខេបឲ្យរៀនផងចុះ ។

---

## កុមារដ្ឋាន

### វិធីបង្ការរោគ

ឯរបៀបបង្រៀនវិធីបង្ការរោគដែលមានរាយខាងក្រោមនេះ សូមគ្រូយកក្មេងណាមួយមកដុសលាងខ្លួនវានៅមុខសិស្សទាំងអស់ ដើម្បីឲ្យវារៀនធ្វើតាមខ្លួនឯងមិនចាំបាច់ម្ដាយឪពុកធ្វើឲ្យ ឯការពន្យល់តែមាត់ទទេមិនគ្រប់គ្រាន់ទេ ។

អាទិត្យទី ១ - ការសំអាតខ្លួនប្រាណ. ។

អាទិត្យទី ២- ការលុបលាងមុខនិងក្អកហើយនិងត្រចៀក

អាទិត្យទី ៣- ការសំអាតក្រចកដៃនិងជើង ។

អាទិត្យទី ៤ ការសំអាតធ្មេញ ។

សូមគ្រូយកច្រាសនិងថ្នាំដុសធ្មេញមកឲ្យក្មេងវាដុសដើម្បីវាចេះប្រើ ចេះសំអាត ។

---

## បរិបូណដ្ឋាន

### វិត្ថុស្វាធ្យាយន៍

### អាទិត្យទី១ អំពីការរំលាយអាហារ

សូមគ្រូគូររូបគ្រឿងប្រដាប់សំរាប់រំលាយអាហារពន្យល់ ហើយបង្ហាញសិស្សឲ្យស្គាល់កន្លែងមាត់បំពង់អាហារ ក្រពះ ពោះវៀន ។

ចោទសួរសិស្សឲ្យឆ្លើយរកការរំលាយអាហារដែលយើងខានមិនបាននោះ-តើអ្វីខ្លះ អាហារដែលយើងបរិភោគទៅ បើមិនរលាយល្អទៅយើងមានជីវិតឬទេ? និងបរិភោគយើងត្រូវការអ្វីខ្លះ ? ។

សេចក្តីសង្ខេប – យើងត្រូវបរិភោគប្រយោជន៍ឲ្យរស់ជីវិត ការដែលបរិភោគអាហារ ហើយរំលាយអាហារឲ្យទៅជាវត្ថុរាវជ្រាបទៅ . ក្នុងឈាមបាននោះហៅថា ការរំលាយអាហារ ។

កាលណាយើងបរិភោគ យើងទំពាអាហារដែលមានទឹកមាត់ផ្សំអាហារធ្លាក់ពីមាត់ទៅបំពង់កទៅក្រពះទៅពោះវៀន នៅក្នុងពោះវៀនអាហារដែលរំលាយស្រេចហើយនោះ ក៏បែកជាពីរចំណែកជាដើម ចំណែកមួយត្រូវនៅក្នុងខ្លួន ចំណែកមួយទៀតត្រូវបញ្ចេញចោលទៅក្រៅ ។

## អាទិត្យទី២ ការដកដង្ហើម

សូមមើលហើយ បង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បរិវច្ឆណដ្ឋានទំព័រទី១៤

## អាទិត្យទី៣ អំពីវិញ្ញាណ៥

វិញ្ញាណប្រាំគឺ កាយវិញ្ញាណ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ជីវ្ហាវិញ្ញាណ និងឃានវិញ្ញាណ ។

សូមមើលសៀវភៅដែលទំព័រទី ២០–២១–២២–២៣–២៤–២៥ ។

## អាទិត្យទី ៤.– ច្បាប់ដើរនៅផ្លូវ

សូមគ្រូមើលមេរៀនក្នុងសៀវភៅដែលទំព័រលេខ ១០៤

# បរិបូណដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១ .– អំពីក្អក និងការថែរក្សាក្អក

សូមមើលមេរៀនក្នុងសៀវភៅវិធីបង្ការរោគទំព័រលេខ ១៨ ។

អាទិត្យទី ២ ._ អំពីត្រចៀក និងការថែរក្សាត្រចៀក

សូមៈមើលក្នុងសៀវភៅដដែលទំព័រ ២២

អាទិត្យទី ៣ .– អំពីធ្មេញ និងការថែរក្សាធ្មេញ

សូមមើលតាមសៀវភៅដដែលទំព័រទី ១៩

អាទិត្យទី ៤ .– អំពីការថែរក្សាសក់

សូមមើលតាមសៀវភៅដដែលទំព័រ ២៣

---

## លោកនីតិ

## សម្រាប់គ្រប់ថ្នាក់

### មេឃុំ

នៅក្នុងឃុំនិមួយៗ មានមន្ត្រីម្នាក់ ជាអាណាព្យាបាលលើឃុំដែលរាជការរដ្ឋបាលឲ្យធ្វើជាមេឃុំ ។

មេឃុំមានស្មៀនម្នាក់ មានជំទប់ក្រុមជំនុំនឹងមេភូមិជួយធ្វើការ ជំទប់មាន ៤ នាក់តាមធម្មតា ។

មេឃុំត្រូវទារពន្ធគ្រប់ជំពូកក្នុងឃុំ ត្រូវទទួលពាក្យបណ្ដឹងពីរាស្ត្រ ហើយផ្សះផ្សាទៀតផង បើគូសត្រូវពុំសុខចិត្តត្រូវបញ្ជូនពាក្យនោះទៅចៅហ្វាយស្រុកតាមរយៈ ដើម្បីឲ្យតុលាការជំនុំជំរះតាមច្បាប់ ។

ពាក្យសួរ.– ភូមិអ្នកនៅក្នុងឃុំណា? អ្នកណាត្រួតត្រាលើឃុំ? មុខក្រសួងមេឃុំយ៉ាងណាខ្លះ? ។ល។

## មនុស្សបំណុះឃុំ

គ្រប់ភូមិគ្រប់ឃុំ នៃប្រទេសកម្ពុជាយើង ពុំមែនមានសុទ្ធតែជាតិខ្មែរទេ គឺមានបរជនដែរ ដូចចិន យួនជាដើម មានរបរកស៊ីផ្សេងពីគ្នាប៉ុន្តែជនទាំងនេះទុកជារាស្ត្របំណុះឃុំដូចគ្នា ពីព្រោះមានទីលំនៅក្នុងរយៈឃុំនោះ ហើយបានបង់ពន្ធគ្រប់ជំពូកជូនរាជការក្នុងឃុំនោះផង ។ បណ្ដាជនក្នុងឃុំត្រូវឲ្យដឹងករណីយកិច្ចរបស់ខ្លួន ។

ត្រូវជួយ ទំនុកបំរុងរាជការឃុំ វេលាដែលមានអាសន្នប្រតិបត្តិតាមច្បាប់បញ្ញត្តិដូចមានខាងក្រោមនេះ ៖

ត្រូវបង់ពន្ធគ្រប់ជំពូកជូនមេឃុំតាមច្បាប់បញ្ញត្តិ

ត្រូវប្ដឹងភ្នាក់ងារឃុំ កាលណាមានមនុស្សទុច្ចរិតឬមនុស្សអាក្រក់ផ្សេងៗ ។

បើចង់ទៅនៅទីកន្លែងណាទៀតត្រូវប្តឹងមេឃុំឲ្យចំណាយឈ្មោះចេញពីបញ្ជីឃុំចាស់

ត្រូវយកកូនទៅសុំបណ្តុះអុតនឹងចាក់ថ្នាំការពារជម្ងឺផ្សេង ៗ បើកូនអាយុបាន ៦ ឆ្នាំហើយត្រូវបញ្ជូនទៅសាលារៀនកុំខាន ។

បើរើសបានវត្ថុអ្វីក្តីឬចាប់បានសត្វពាហណៈក្តី ដែលពុំមានម្ចាស់ត្រូវដឹកនាំយកទៅឲ្យភ្នាក់ងារឃុំយ៉ាងឆាប់ បើមានកូនកើតឬស្លាប់ឬធ្វើបុណ្យផ្សេងៗ ត្រូវប្តឹងមេឃុំ ។

ពាក្យសួរ .— យ៉ាងដូចម្តេចដែលហៅថាមនុស្សចំណុះឃុំ ? ករណីយកិច្ចបណ្តាជនក្នុងឃុំត្រូវធ្វើដូចម្តេចខ្លះ ? ។ល។

## អំពីស្រុក

ឃុំច្រើនរួមបានជាស្រុក ។ ក្នុងស្រុកនីមួយៗ មានមន្ត្រីម្នាក់ងារជាចៅហ្វាយស្រុក ជាអ្នកត្រួតត្រាមើលការខុសត្រូវលើស្រុក ។

ចៅហ្វាយស្រុកមានបាឡាត់ស្រុក យោក្របត្រឬស្មៀននឹងប៉ូលិសជួយធ្វើការ ។ ក្រសួងចៅហ្វាយស្រុកដូចមានខាងក្រោមនេះ ។

១.– ត្រូវធ្វើឲ្យរាស្ត្របានសេចក្តីសុខ បំបាត់ចោរកំណាចចេញពីក្នុងស្រុក ដើម្បីឲ្យបានចំរើនខាងកោតសម្បត្តិ ហើយឲ្យដឹងសេចក្តីក្រខ្សត់អត់ឃ្លាននៃបណ្តារាស្ត្រទៀតផង ។

២.– ត្រូវរៀបចំស្រុកឲ្យបានថ្កើងរុងរឿង ធ្វើផ្លូវធ្វើស្ពាន ជីកព្រែកឲ្យចំរើនជនបាននឹងផ្លូវកាត់គ្នាទៅវិញទៅមកដល់ស្រុក ។

៣.– ត្រូវប្រឹងប្រែងខំប្រមូលប្រាក់ពន្ធពីមេឃុំនានាយកទៅដាក់ឃ្លាំងឲ្យបានទាន់ពេលវេលា ។

៤.– ត្រូវទូន្មានពន្យល់បណ្តារាស្ត្រក្នុងស្រុកឲ្យប្រព្រឹត្តត្រឹមត្រូវ ពន្យល់អំពីរបៀបរកស៊ីអំពីវិទ្យាសាស្ត្រដើម្បីបំបាត់សេចក្តីល្ងង់ខ្លៅចោលចេញ ។

ពាក្យសួរ.– ឃុំអ្នកនៅក្នុងស្រុកណា? យ៉ាងដូចម្តេចដែលហៅថាស្រុក? នៅក្នុងស្រុកនីមួយៗ មានមន្ត្រីណាខ្លះ? ចៅហ្វាយស្រុកធ្វើអ្វីខ្លះ?

## អំពីខេត្ត

ស្រុកច្រើនរួមកើតបានជាខេត្ត មានមន្ត្រីម្នាក់ជាន់ខ្ពស់ងារជាចៅហ្វាយខេត្តត្រួតត្រា មើលការខុសត្រូវលើចៅហ្វាយស្រុក និងមន្ត្រីឯទៀត

នៅក្នុងខេត្ត ។ នៅប្រទេសកម្ពុជាមាន១៤ខេត្តគឺៈ ខេត្តកណ្ដាល - កំពង់ស្ពឺ - តាកែវ - កំពត - ព្រៃវែង - ស្វាយរៀង - កំពង់ចាម - ក្រចេះ - ស្ទឹងត្រែង - កំពង់ធំ - កំពង់ឆ្នាំង - ពោធិ៍សាត់ - សៀមរាប - បាត់ដំបង ។

ក្រសួងចៅហ្វាយខេត្តដូចមានខាងក្រោមនេះ

១.— ត្រូវប្រមូលប្រាក់ពន្ធគ្រប់មុខពីចៅហ្វាយស្រុក ។

២.- ត្រូវរៀបចំខេត្តឲ្យបានចំរើនរុងរឿងឲ្យបានសន្តិសុខនឹងចំរើននូវភោគសម្បត្តិ ។

៣.— ត្រូវទទួលពត៌មានផ្សេងៗ ពីចៅហ្វាយស្រុកហើយពិនិត្យមើលឲ្យបានត្រឹមត្រូវរួចបញ្ជូនទៅតាមក្រសួង ។

៤.— ត្រូវទទួលច្បាប់បញ្ញត្តិនានាអំពីរដ្ឋមន្ត្រីៈហើយចាត់ការបង្គាប់ទៅចៅហ្វាយស្រុកឲ្យប្រតិបត្តិតាម ។

---

# មេសូត្ររត់មាត់

(សំរាប់គ្រប់ថ្នាក់)

## —បន្ទប់រៀន

| | | |
|---|---|---|
| សាលារៀនខ្ញុំ | បែកជាបីក្រុម | ខណ្ឌជញ្ជាំងឥដ្ឋ |
| ថ្នាក់ដែលខ្ញុំរៀន | កុមារដ្ឋានពិត | ប្រតិស្ឋនៅជិត |
| មាត់ទ្វារចូលហោង | ៗបន្ទប់ធំល្ហម | មានទ្វារមួយព្រម |

បន្ទប់ច្រើនផង នៅក្នុងបន្ទប់ មានគ្រប់ឥតហ្មង
តុកៅអីផង របស់គ្រូខ្ញុំ ៗ ក្តារខៀនបញ្ឈរ
នៅលើឈើទ្រ មិនតូចមិនធំ ពីរជិតជញ្ជាំង
អមតុគ្រូខ្ញុំ គេបានរៀបចំ សមជាថ្នាក់រៀនៗ
មានតុជើងម៉ា របស់សិក្សា រៀងរាល់រូបប្រាណ
គេរៀបពីរជួរ ស្មើឥតលើសលាន កណ្តាលនោះមាន
ចន្លោះទូលំ ៗ នៅក្នុងបន្ទប់ មានផែនទីគ្រប់
នគរខេត្រឃុំ គំនូរមនុស្សសត្វ ខ្លះតូចខ្លះធំ
គេព្យួរជិតជុំ ភ្ជាប់ជញ្ជាំងនោះ ៗ បន្ទប់រៀនខ្ញុំ
ស្អាតហើយសមរម្យ គ្មានធូលីសោះ គួលីសំអាត
ប្រោសគ្មានចន្លោះ ថ្ងៃណាមួយសោះ ពីព្រោះការពារ ៗ
កុំឲ្យស្មោគគ្រោក បង្កើតមេរោគ ដល់សិស្សគ្រប់គ្នា
បណ្តាលឲ្យឈឺ ជម្ងឺខ្លាំងក្លា ជូនមើលពុំជា
ស្លាប់ទៅក៏មាន ៗ

ពាក្យពន្យល់ ៈ- ប្រតិស្ឋ = (ម. ថ. ប្រដិស.) បិតនៅ, តាំងនៅ ៗ
ទូលំ : ត្រូវនឹងពាក្យថាទូលាយ (ទូលំទូលាយ)

# ក្របី

| | | |
|---|---|---|
| ក្របីខ្លួនធំ | ខ្ពស់មាឌរាងមាំ | កំឡាំងជាងគោ |
| រោមតិចពណ៌ពីរ | ប្រផេះលាយស | ខ្មៅដើរឬឈរ |
| អើតលើខុសគេ ៗ | ស្នែងវាធំវែង | ហើយខុបកោងវែង |
| ទៅក្រោយទាំងទ្វេ | ដើរយឺតជាងគោ | តែស៊ូតបូតទេ |
| ចិត្តធ្ងន់ជាងគេ | ប៉ុនអត់អាហារ ៗ | ទោះតិចណាជាតិ |
| តិចតួចក៏ធៀត | បំអែតអាត្មា | មានទឹកទឹងភក់ |
| ជាទីស្នេហា | អាចធ្ងន់គគ្គា | ឬព្រែកបឹងបាន ៗ |
| គេតែងប្រើវា | ភ្ជួរស្រែចំការ | រាល់ឆ្នាំពុំខាន |
| បើអូសរទេះ | ក៏អាចអូសបាន | ឬធ្វើជាយាន |
| ដោយខ្នងវែងវា ៗ | សាច់ពុំស៊ូវឆ្ងាញ់ | មានរសជាតិចាញ់ |
| សាច់គោទេណា | ស្បែកវាគឺគេ | តែងតែត្រូវការ |
| កាត់ច្រៀកវេញជា | ព្រ័ត្រត្រៀមរទេះ ៗ | ឬក៏ចងអ្វី |
| បានជាប់ពេកក្រៃ | មិនដាច់របេះ | ឬបើទឹងគិត |
| ពិនិត្យត្រិះរិះ | ពាសស្គរដូចេះ | ស្បែកដើងបានទៀត ៗ |
| ប្រយោជន៍នៃស្នែង | គេអាចកាត់តែង | ដងកាំបិតស្នៀត |
| ឬកាំបិតអ្វី | ដទៃទៅទៀត | ឬក៏អាចធៀត |

ធ្វើខ្នាក់ផ្ការ ៗ  នេះជាប្រធាន  គ្រប់អាចមាន
ប្រយោជន៍ណាស់នៃ  វាជាសត្វស្រុក  ស្រណុកប្រើក្រៃ
ទាំងយប់ទាំងថ្ងៃ  ពុំដែលរួញរា ៗ

ពាក្យពន្យល់.–

គុណជាតិ = ម. ថ. គុណ:ជាតិ ជាតិស្មោះ ៗ ព្រ័ត្រ = ម. ថ. ព្រាត់ ស្បែកសត្វយកមកច្រៀកវេញធ្វើជាខ្សែពួរ ៗ

## ព្រះបរមរាជវាំង

នៅក្រុងភ្នំពេញមាន  រាជដ្ឋានដ៏បវរ
ប្រសើរពិសិដ្ឋសម  យ៉ាងឧត្តមមហាស្ចារ្យ ៗ
ជុំវិញព័ទ្ធព័ទ្ធជិត  កំពែងឥដ្ឋមានក្លោងទ្វារ
បែរមុខចំគង្គា  ដែលនាមថាចតុមុខ ៗ
ខាងក្នុងព្រះរាជវាំង  មានទីនាំងខ្ពង់ខ្ពស់ស្កុក
ដែលគេរចនាទុក  បំរុងរាជរបស់ស្តេច ៗ
ទេពវិនិច្ឆ័យ  ធំពេកក្រៃល្អបណ្តាច់
ដំបូលគេសំរេច  ច្រើនជំរួតរូបគ្រុឌទ្រ ៗ
កំពូលមានព្រះភក្ត្រ  ព្រះព្រហ្មជាក់បែបត្រេកអរ

ញញឹមឥតឈប់ឈរ　　ឆ្ពោះទៅគ្រប់ទិសបួនពិត ។
កំពូលត្រីសូល៍ខ្ពស់　　លើសគេអស់តាមពិនិត្យ
ទីនាំងខាងក្នុងពិត　　បរិបូណ៌រាជគណ្ឌ ។
មានតាំងព្រះបល្ល័ង្ក　　ស្វេតច្ឆត្រប៉ាំងប្រាំបួនជាន់
គួរតែយើងគ្នេរគ្នាន់　　សរសើរបុណ្យព្រះរាជា ។
មានមហាប្រាសាទ　　ខេមរិន្ទស្អាតយ៉ាងសោភា
ដំណាក់ព្រះរាជា　　ទ្រង់ប្រថាប់ដោយក្សេមក្សាន្ត ។

ពាក្យពន្យល់.— រាជដ្ឋាន = លំនៅស្តេច ទីស្តេច ។

បរម = (ម.ថ. បរ៉ុម) ប្រសើរ, ក្រៃលែង ។

ពិសិដ្ឋ=(ម.ថ.ពិសិត)ដែលឧត្តម, ខ្ពង់ខ្ពស់ ។

មហស្ចារ្យ=(ម.ថ.មៈហ័សស្ចា) អស្ចារ្យធំ ។

ត្រីសូល៍=(ម.ថ. ត្រីសូ)ដែលមានកំពូលបី ។

រាជ័គណ្ឌ=(ម.ថ. រាជ័គន) ព្រះរាជទ្រព្យ ។

សោភា = ដែលស្អាត ។ ប្រថាប់ = គង់នៅ ។

## កំណើតនគរកម្ពុជា បណ្ដាជនដើម

កាលដើមនគរខ្មែរ　　មានសុទ្ធតែទឹកសមុទ្រ
ទន្លេធំមោះមុត　　ដែលមានឈ្មោះថាមេគង្គ ។

រាល់ឆ្នាំតែងនាំល្បប់ មកបាក់សព្វៈពេញកំពង់
ពេញអស់នៃអន្ទង់ ច្រើនអនេកឥតគណនា ៗ
ឯកោះដែលចាស់ ៗ ប្រាកដច្បាស់ក្លាយទៅជា
បពិត្រខ្ពស់មហិមា ដែលតាំងនៅកណ្ដាលវាល ៗ
ពួកខ្មែរដើមគឺជ្វា សុវណ្ណតាមដំណាល
ថ្ងៃក្រោយគឺបណ្ដាល ឲ្យជ្វាព្រាហ្មស្រុកកោះជ្វា ៗ
ចូលមកលុកទន្ទ្រាន តាមជលផ្លានសមុទ្រ
ហើយមានជាតិកម្ពុជា ស្រុតឈ្លៀចូលមកទៀត ៗ
ពីខាងទិសពាយ័ព្យ ដោយលើកទ័ពចូលប្រជ្រៀត
មកនៅលាយឡំជាតិ បានជាក្លាយខុសធម្មតា ៗ
ឯជ្វាព្រាហ្មណ៍សោតទៀត នឹងឯជាតិកម្ពុជា
សម្បុរខ្មៅដូចគ្នា ច្នេះបានជាខ្មែរច្រើនខ្មៅ ៗ
ពីព្រោះជាពូជកាត់ ដូច្នេះបាត់ជាហ្វង់សៅ
ជាតិពីរក្លាយចូលទៅ ថែមជាតិជ្វាដើមមួយទៀត ៗ
នគរកម្ពុជា មាននាមក្លាយពីជាតិ
កម្ពុជាដែលប្រជ្រៀត មកសំណាក់អាស្រ័យនៅ ៗ

ពាក្យពន្យល់ :- បតិត = (ម.ជ. បរពត់) ក្តី ៗ
សុវណ្ណ = (ម. ជ. សុវណ្ណ) ពណ៌ល្អ, ពណ៌ស្រះ ៗ ផលស្ថាន = (ម.ជ. ផលត្ថាន) ទីទឹក ៗ សមុទ្ទ = (ម. ជ. ស. មុ៉ត-ទា) បានដល់សមុទ្រ ៗ

# ករណីយកិច្ចរបស់មនុស្ស

គាពមនុស្សគ្រប់រូបប្រាណ  តែងតែមានអំណាចមួយ
ធម្មជាតិប្រគល់ឲ្យ  ពីកំណើតគឺខួរក្បាល ៗ
មនុស្សណាមានខួរល្អ  នោះកម្រគេផ្ចាញ់ផ្ចាល
ប្រាជ្ញាឈ្លាសគ្រប់កាល  អាចត្រិះរិះរកហេតុផល ៗ
ស្គាល់ការណ៍នឹងអការណ៍  កម្មន្តមិនអំពល់
ឬទុក្ខមុខយល់  ប្រតិពលយ៉ាងប្រត្យក្ស ៗ
គោលការណ៍យ៉ាងណាក្តី  វិនិច្ឆ័យឲ្យច្បាស់ជាក់
ព្រឹត្តិការណ៍ដែលទើសទាក់  អាចបញ្ជាក់ដោយប្រាជ្ញា ៗ
ដំណើរនេះធ្វើជាតិ  មនុស្សឲ្យឃ្លាតពាតទុក្ខា
ឲ្យខ្ពង់ខ្ពស់ថ្លៃថ្លា  ជាងសត្តានានលោកិយ ៗ

ចំណែកផលសំរេច    ច្រើន ឬ តិចតូចធំក្តី

កើតដោយសារស្នាដៃ    នៃមនុស្សជាតិទាំងសកល ។

ពាក្យពន្យល់.– ករណីយកិច្ច = ការ ឬ អំពើដែលត្រូវធ្វើ ។

អការណ៍ = (ម.ថ. អ័ក កា) មិនមែនហេតុ ។

កម្មន្តា = (ម.ថ. កាំ ម៉ន់ តា) ការងារ ។

ប្រតិពល = (ម.ថ. ប្រតិពល់) ដែលអង់អាច, ហានរៃ, ស្ទាត់ ។

ព្រឹត្តិការណ៍ = ហេតុដែលកើតឡើងក្នុងលោក

សត្តា = (ម.ថ. ស័ត តា) សត្វទាំងឡាយ ។

---

## ៦ – ករណីយកិច្ចរបស់មនុស្ស (ត)

សព្វសត្វជាឧបករណ៍    ជួយគាំទ្រតែកាយពល

មនុស្សប្រើប្រយោជន៍ដល់    មនុស្សផងគ្នាដោយប្រាជ្ញា ។

មនុស្សជាអភិបាល    បញ្ញាក្រាលគ្រងរក្សា

ពារពិភពលោកា    ពប់សែនលានឆ្នាំអនេក ។

ឋិតនៅក្នុងលោកនេះ    ដកបប្រេះផ្កាយបាក់បែក

នូវលោកគ្មានសល់ផ្នែក    គឺសាបសូន្យរលាយទៅ ។

យើងត្រូវដឹងដូច្នេះ ថាមនុស្សនេះអ្នកបិតនៅ
គ្រាភាពឥតហ្វូវសៅ គឺអាចប្រឹងការពារលោក ។
យើងត្រូវធ្វើដំកប់ យកវាច្បាប់ហើយត្រូវក្រោក
ប្រឹងស្វយនាំទ្រលោក ឲ្យស្រុះក្រោករកវឌ្ឍនៈ ។
ត្រូវប្រើសមត្ថភាព តាមរបៀបជនពិទ័គ្ឍ
សម្រាលឧបសគ្គ ឲ្យកើតតែសន្តិសុខ ។
ក្រោមតាំងការ្យធម៌ ផ្សុកុះការទការស្រុក
ថ្លៃថ្នូរប្រសើរសុខ តទៅមុខក្សេមសប្បាយ ។
ធ្វើខ្លួនឲ្យរុងរោចន៍ មានប្រយោជន៍ល្បីខ្ចរខ្ចាយ
កេរ្តិ៍ឈ្មោះពីរោះផ្សាយ ដល់សាកលពិភពលោក ។

## ពាក្យពន្យល់

ឧបករណ៍ = គ្រឿងទាំងឡាយដែលសំរាប់យើងប្រើប្រាស់ ។ កាយពល = ( ម. ថ. កា - យៈ - ពល់ ) កម្លាំងកាយ ។ អភិបាល = ( ម. ថ. អភិ បាល ) អ្នកគ្រប់គ្រង អ្នកថែរក្សា ។ វឌ្ឍនៈ = ( ម. ថ. វ័ឌ ឍៈ នៈ ) សេចក្តីចំរើន ។ សមត្ថភាព ភាពនៃសេចក្តីអាចហាន ។ ពិទ័គ្ឍ = ( ម. ថ. ពិទ័ក ) ប៉ិនប្រសប់ ។ ការ្យធម៌ = ធម៌ដែលនាំឲ្យកើតសេចក្តីចំរើន ។ រុងរោចន៍ = ដែលរុងរឿង ភ្លឺផ្លេក ។

រោងពុម្ពខ្មែរ